

# គួច គីឡេង

(KUOCH Ky Leng)
(1930-1975 ?)

ប្រមូលឯកសារដោយ

## *បណ្ឌិតសភាចារ្យ ឃីងហុកឌី*

*លោកគួចគីឡេងជាអតីតសាស្ត្រាចារ្យនៅវិទ្យាល័យក្រុងតាខ្មៅ ក្នុងទីរួមខេត្តកណ្ដាល។*

- *កើតនៅថ្ងៃ ទី១៥ ខែ មករា ឆ្នាំ១៩៣០ក្នុងឃុំទឹកវិលស្រុកស្អាងក្នុង ខេត្តកណ្ដាល។*

- មានបរិញ្ញាប័ត្រ ជាន់ខ្ពស់ផ្នែក ភាសាបាលីនៅសាលាប្រទេសឥណ្ឌា ក្រុងដេលីនិងបានបរិញ្ញាប័ត្រផ្នែកអក្សរសាស្ត្រ ភាសារអង់គ្លេស , សង្គមវិទ្យា , ប្រវត្តិវិទ្យា, និង វិទ្យាសាស្ត្រនយោបាយ ។
- លោកបានបន្តការសិក្សានៅសហរដ្ឋអាមេរិករហូតដល់បាន សញ្ញាប័ត្រ អនុបណ្ឌិតផ្នែកសិក្សាធិការអប់រំជាតិ (MA) នៃសកលវិទ្យាល័យក្នុង ទីក្រុង អូហៃយូ (Ohio)។ (សូមអានជីវប្រវត្តិសង្ខេបសរសេរដោយលោកផ្ទាល់នៅលើគ្របសៀវភៅរបស់លោក)។
- លោកគ្រូគួចគីឡេងប្រហែលលោកអនិច្ចកម្មនៅសម័យខ្មៅងងឹតនៃប្រទេសកម្ពុជារវាងឆ្នាំ១៩៧៥ (?)។
- ឯកសារ ដែល សរសេរ ចងក្រង ជាសៀវភៅ និងបានបោះពុម្ព ផ្សាយ មាន សៀវភៅ *វីរៈពលរដ្ឋ* បោះពុម្ពនៅឆ្នាំ១៩៧០ មាន២ភាគ (ភាគ១មាន៨៤ ទំព័រ និង ភាគ ២ មាន៦៣ទំព័រ)។

នេះទំព័រក្របក្រៅ




ទំព័រទី១



### ភាគទី១មាន៨៤ ទំព័រ ៖

ជាបឋម ក្នុង អារម្ភកថា លោកបានស្រង់សំដីទស្សនវិទូ បុរាណជន ជាតិក្រិចម្នាក់នាមអារីស្តូត (Aristote) ស្តីពី«គោលដៅនៃរដ្ឋពុំមែនគ្រាន់តែបានរស់ នៅទាំងអស់គ្នានោះទេ គឺសំដៅយកគុណភាពល្អនៃការរស់នៅ» ក្នុងអារម្ភកថាទាំងមូលលោកខំបង្ហាញពីវាក្យស័ព្ទ «លទ្ធិ» ដោយបានឲ្យនិយមន័យ ហើយលោកទុក ដូច ជា «ឱសថ» សម្រាប់ព្យាបាល រោគផ្សេងៗ ហើយលោកបានបញ្ចប់អារម្ភកថាលើសម្រែកជយឃោសថា៖

«ជយោ សាធារណរដ្ឋខ្មែរ»!

បានសេចក្តីថា លោកសាស្រ្តា គួចគីឡេង កាន់នយោបាយខាងសាធារណរដ្ឋ ដែលទើបនឹងបដិសន្ធិឡើងនាឆ្នាំ១៩៧០។ល។ ភាគទី១នេះ លោកគួចគីឡេង ធ្វើសេចក្តីអធិប្បាយបែប សង្គមវិជ្ជានយោបាយដែលជាវិជ្ជាឯកទេសលោកពីលទ្ធផលបានសិក្សានៅសកលវិទ្យាល័យនៅបរទេស។

ក្នុងភាគទី១នេះ ដោយលោកគួចគីឡេងចែកចេញជា៤ជំពូកធំៗ៖

១) គោលដៅនៃវិជ្ជាពលរដ្ឋ,

២) សង្គម,

៣) រដ្ឋ,

៤) រដ្ឋ, ប្រជាជាតិ, សញ្ជាតិ និង ជាតិនិយម។

ភាគ ២ មាន៦៣ទំព័រ៖

លោកគួចគីឡេង បានបង្ហាញជាពិសេស ២ចំណុចធំៗ គឺ ដោយបានផ្អែកលើគំនិតទស្សនវិទូ៣រូបនៅអ៊ឺរ៉ុប គឺ៖ ហុប្ស (Thomas HOBBES, 1588-1679), ឡុក (John LOCKE, 1632-1704) និង រូស្សូ (Jean-Jacques ROUSSEAU)។

នៅទីបញ្ចប់ លោកគួមគីឡេងបង្ហាញពី ទ្រឹស្ដីទំនើប ស្ដី ពីការវិវត្តន៍នៃរដ្ឋ។

## ស្នាដៃចុងក្រោយរបស់លោកគួចគីឡេង

ស្នាដៃនេះលោកបានសរសេររវាងឆ្នាំ១៩៧៣នា ពេល មានចលនាកូដកម្ម នៅមហាវិទ្យាល័យគរុកោសល្យភ្នំពេញ នាថ្ងៃ១៧ខែមិនា១៩៧៣ តែស្នាដៃនេះបានបោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ១៩៧៥គឺប៉ុន្មានខែមុន កម្ពុជាធ្លាក់ក្នុងកណ្ដាប់ដៃ ខ្មែរក្រហម។

ស្នាដៃនេះដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធសិស្ស ពីរ នាក់ដែលបានបាត់ បង់ជីវិតក្នុងមហាវិទ្យាល័យគរុកោសល្យ។

នេះរូបក្របសៀវភៅចុងក្រោយរបស់លោក គួចគីឡេង (កម្មសិទ្ធិលោកអ៊ុចកិរម្យនិងលោកគ្រូ សេងសុវណ្ណដារា)៖


គួច-គីឡេង

ខាងក្រោមនេះជារូបថត ក្របទំព័រទី៤៖



សូមឧទ្ទិសចំពោះវិញ្ញាណក្ខន្ធនៃសិស្សពីររូប ដែលបានបាត់បង់ជីវិតនៅក្នុងមហាវិទ្យាល័យគរុកោសល្យ នៅថ្ងៃទី ១៧ មីនា ឆ្នាំ ១៩៧៣

ដំកល់ទុកនៅបណ្ណាល័យជាតិ តាមលេខ ៨២ ចុះថ្ងៃទី ២២ កុម្ភៈ ១៩៧៥ ។ លើកទីមួយចំនួន ១០០០ ច្បាប់ បោះពុម្ពនៅគ្រឹះស្ថាន មិត្តភាព លេខ ៧២ ផ្លូវ ៣២៩

ខាងក្រោមនេះគឺរូបភាពខ្លះៗបង្ហាញពីទិដ្ឋភាពនាពេលកូដកម្មដែលស្រង់ពីសារពត៌មាន«នគរធំ»៖



ខាងក្រោមនេះជាសម្រង់ចេញពីសៀវភៅកូដកម្ម ដែលកនិពន្ធដោយកម្មករត្រីចក្រយានម្នាក់ ហើយកំណាព្យនេះទៀតសោត សូត្រដោយអ្នកគ្រូម្នាក់ ដែល កវីនិពន្ធ «អ៊ូច ស៊ីន»ដែលបានផ្តល់ស្នាដៃ ជាកំណាព្យនេះដល់គណៈកម្មការកូដកម្មបុគ្គលិកសិក្សា៖



រូបថត: នគរធំ ។ អ្នកគ្រួសូត្រកំណាព្យ។ ( កំណាព្យទាំងពីរបទនេះ ជាស្នាដៃរបស់លោក អ៊ូច - ស៊ុន កម្មកររត្រិចក្រយាន ដែលបានចូលជាវិភាគទាន ដល់គណៈកម្មការកូដកម្មបុគ្គលិកសិក្សា ។

# ពុករលួយ

អំពើពុកផុយ ស្អុយរលួយ
លបលួចបូមពួយប្រាក់ថវិកា
ទិញមាសទិញពេជ្រឡានវីឡា
ដីកស៊ីហ៊ីហាស្រាស្រីល្បែង ។
ប្រពន្ធពីរបីសាច់ខ្ចីល្ងក់
រង្វើងផ្គួតឈ្លក់ភ្លេចជាតិឯង
បរិភោគច្រើនស្ដាំរត់ខ្វាត់ខ្វែង
សំឡុតកំហែងអ្នកតូចតាច ។
អំពើពុកផុយ ស្អុយគគ្រិច
ជិះជាន់ពន្ទិចខាងអំណាច
ហុតឈាមជាតិឯងដូចបិសាច
មិនខ្លាចខុសច្បាប់ពាលព្រៃផ្សៃ ។
អំពើពុកផុយ ស្អុយរលួយ
ជាមេរោគមួយកាចចង្រៃ
ទុកយូរស៊ីរូងជាតិក្សិណក្ស័យ
គ្មានថ្ងៃធីងរស់ស្លាប់អន្តរាយ ។
អំពើពុកផុយ ស្អុយរឡេះ
សង្គមធាបនេះក្ដៅក្រហាយ
ពលរដ្ឋវេទនាមិនសប្បាយ
រដ្ឋអន្តរាយក្លាយជាទុក្ខ ។
ត្រូវតែបំបាត់កុំឲ្យសល់
ដីកឫសកាប់គល់កុំយល់មុខ
កំពូជពុកផុយ ស្អុយកុំទុក
ជាដង្កូវរុកជញ្ជក់ជាតិ ។

# ជីវប្រវត្តិសង្ខេបលោកគ្រូគួចគីឡេងលើក្របសៀវភៅលោក៖



កើតក្នុងឆ្នាំ ១៩៣០ នៅឃុំទឹកវិល ស្អាង កណ្ដាល ក្នុងគ្រួសារកសិករមធ្យមមួយ លោក **គួច-គីឡេង** បានសិក្សានៅសាលាបឋមសិក្សាបំពេញវិជ្ជាបារាំង - ខ្មែរ ហើយបន្ទាប់មកទៅសាលាបាលីជាន់ខ្ពស់ទៀត ។ ក្នុងឆ្នាំ ១៩៥២ លោកបានទៅនៅប្រទេសឥណ្ឌា ហើយសិក្សាអស់រយៈកាល ២ ឆ្នាំ ក្នុង International Academy of Indian Culture ។ ក្នុងឆ្នាំ ១៩៥៩ លោកបានទទួលសញ្ញាបត្រ Bachelor of Arts ផ្នែកអក្សរសាស្ត្រ, វិទ្យាសាស្ត្រនយោបាយ, ទស្សនវិជ្ជានិងប្រវត្តិសាស្ត្រ ពីសកលវិទ្យាល័យដេលី ហើយបានបន្តការសិក្សានៅសហរដ្ឋអាមេរិកទៀត រហូតដល់បានទទួលសញ្ញាបត្រ Master of Education ជាពិសេសផ្នែកអក្សរសាស្ត្រ, ភាសាសាស្ត្រ, ការអប់រំ និង Orientation ពីសកលវិទ្យាល័យអូហៃយ៉ូ ។

ការព្រួយបារម្ភរបស់លោកចំពោះការបាត់បង់ទឹកដី និងអាយុយឺនយូរនៃរបបសាធារណរដ្ឋនិយមថ្មីថ្មោងយើងនេះ បាននាំឲ្យលោកចងក្រងសៀវភៅ **«គំនិតនយោបាយ»** នេះឡើង ដើម្បីជាពន្លឺនៃការពិចារណាដល់បងប្អូនរួមជាតិគ្រប់ៗរូប ។

**រោងពុម្ព មារយើង** **តម្លៃ** 50៛

សេចក្ដីបញ្ជាក់ចុងក្រោយកំណត់នេះៈ

ប្រសិនបើអស់អ្នកស្រាវជ្រាវចង់ដឹងសេចក្ដីពិស្ដារ សូមអញ្ជើញអានស្នាដៃលោកគ្រូ គួចគីឡេង តម្កល់រក្សាទុក នៅបណ្ណាល័យឯកទេសនានា លើឯកសារប្រទេសកម្ពុជាប៉ារីសហើយជា ពិសេស គឺនៅបណ្ណាល័យជាតិនិងបណ្ណសារជាតិក្រុងភ្នំពេញ។ល។

ស្នាដៃគួចគីឡេង សហការ ជាមួយ  ម៉ែលន់

បោះផ្សាយឆ្នាំ១៩៧២នៅភ្នំពេញ។



កាលបានទៅធ្វើការងារជាសាស្ត្រាចារ្យបឋមភូមិនៅ
វិទ្យាល័យសន្តិភាពក្នុងខេត្តកំពង់ស្ពឺ បានចូលជាសមាជិកក្នុង
សមាគមបុគ្គលិកសិក្សាខ្មែរ ហើយនៅក្នុងទីរួមខេត្តនេះមាន
លោកសាស្ត្រាចារ្យ យី-យន់ ជាប្រធានគណៈកម្មាធិការ
សមាគមនេះ។ លោកត្រូវជាបងថ្លៃ ឯ,ឧ ឯកសំអុល ជាអតីត
ប្រធានគណរដ្ឋធម្មនុញ្ញកម្ពុជា ហើយ បច្ចុប្បន្ន ឯ,ឧ. ជាប្រធាន
តុលាការកំពូល។

នេះសម្បក ក្របខ្នងអត្តសញ្ញាណប័ណ្ណ៖



ខាងក្រោមនេះគឺសម្បកអត្តសញ្ញាណប័ណ្ណខាងក្នុង៖



គួច-គីឡេង ម៉ៃ-លន់

# ជុំវិញព្រឹត្តិការណ៍រំលាយ
# សមាគមបុគ្គលិកសិក្សាខ្មែរ

សៀវភៅឯកសារប្រវត្តិសាស្ត្រ

Prix 3 F 00 — Tuol Tapoung 19.5.81

# ជុំវិញព្រឹត្តិការណ៍រំលាយ សមាគមបុគ្គលិកសិក្សាខ្មែរ


ចងក្រងដោយ

**ម៉ៃ - លន់**

**គួច - គីឡេខ**



ផ្សាយចេញពី

ទីស្នាក់ការអចិន្ត្រៃយ៍នៃសមាគមបុគ្គលិកសិក្សាខ្មែរ
លេខ ៥ , វិថី ឧកញ៉ាម៉ែន, ភ្នំពេញ

ព. ស. ២៥១៨ គ. ស. ១៩៧៤

ក្នុងរបបប្រជាធិបតេយ្យប្រជាប្រិយ :

រដ្ឋាភិបាលដោយប្រជារាស្ត្រ, របស់ប្រជារាស្ត្រនិងដើម្បីប្រជារាស្ត្រ

Abraham Lincoln

ក្នុងរបបប្រជាធិបតេយ្យលាក់ខ្លួន :

រដ្ឋាភិបាលផ្ដាច់ការសមានកម្ម, ឃ្លាតចាកប្រជារាស្ត្រ និងរង្វេងប្រជារាស្ត្រ ។

គ. គ. ឡ.

" គ្មានពលរដ្ឋអាមេរិកាំងណាមួយនៅលើច្បាប់បានឡើយ " ។

ចៅក្រមអាមេរិកាំង

" ខ្ញុំគ្មានអាវុធដូចលោកទេ ប៉ុន្តែទឹកចិត្តប្ដូរផ្ដាច់នៃជនជាតិខ្ញុំ គឺជាអាវុធរបស់ខ្ញុំ " ។

**មហាត្មាគន្ធី**

( និយាយចំពោះមុខឧបរាជអង់គ្លេស )

" ប្រជាធិបតេយ្យគ្មានអ្នកដឹកនាំគឺអនាធិបតេយ្យ តែបើអ្នកដឹកនាំគ្មានលទ្ធិប្រជាធិបតេយ្យគឺជាលទ្ធិផ្ដាច់ការ " ។

ប្រធានាធិបតី **ស៊ូហារតូ**

" ម្នាលភិក្ខុទាំងឡាយ ! ចូរញាណ ( ពន្លឺគំនិត ) កើតមានដល់អ្នកទាំងឡាយគ្រប់រូប ។ ចូរកុំធ្វើខ្លួនឲ្យជាទាសៈនៃលោកៈ " ។

**ព្រះសម្មាសម្ពុទ្ធ**

ផេគ្គុ ហោតិ ផេគ្គុបរិវារោ (ឈើ) ពុក តែងតែយកឈើពុកជាបរិវារ ។

**ព្រះសុត្តន្តបិដក**

សៀវភៅ

# ក្រសួងអប់រំពុករលួយ

ដោយ គួច- គីឡេង

បានត្រូវអាជ្ញាធរហាមឃាត់មិនឲ្យលក់ជាសាធារណៈ តាមលិខិតក្រសួងឃោសនាការលេខ ៨៥១ ខសជ ចុះថ្ងៃទី ១៧ វិច្ឆិកា ១៩៧៤ ។

# កថាមុខ

យើងរៀបចំកូនសៀវភៅនេះ ដើម្បីជាឯកសារនៃព្រឹត្តិ-ការណ៍ ដែលបានបោកបក់មកលើសមាគមបុគ្គលិកសិក្សាខ្មែរ កាលពីថ្ងៃទី ២៥ កញ្ញា ១៩៧៤ ។

ដោយពេលវេលាខ្លី យើងចៀសវាងនូវអត្ថាធិប្បាយវែងឆ្ងាយ ហើយគ្រាន់តែរៀបរាប់តាមលំដាប់នូវព្រឹត្តិការណ៍ប្រវត្តិ-សាស្ត្រនេះចាប់ពីថ្ងៃដែលអាជ្ញាធរបានរំលោភលើច្បាប់រដ្ឋធម្ម-នុញ្ញ រំលោភលើសិទ្ធិសេរីភាពប្រជាពលរដ្ឋ និងបានរំលោភលើសមាគមមួយ ដែលមានចំណាស់ជិតសាមសិបឆ្នាំមកហើយ ដែលធ្វើឱ្យមតិជាតិនិងអន្តរជាតិ ជាពិសេសមិត្តសមាជិកសមា-ជិកា នៃសមាគមមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

ចលនាទាមទារឱ្យអាជ្ញាធរបើកសមាគមឡើងវិញ ក៏បានចាប់ផ្ដើមមានឡើង តាំងពីថ្ងៃដែលសមាគមត្រូវគេរំលាយដែរ ហើយចលនានេះកំពុងតែវិវត្តយ៉ាងលឿនរហាស់ជារាល់ថ្ងៃ ។

សៀវភៅតូចនេះមានភារៈគ្រាន់តែបង្ហាញនូវប្រតិកម្មភាគដើមនៃចលនាខាងលើ ដែលលេចចេញពីមជ្ឈដ្ឋាននានា តែប៉ុណ្ណោះ ដើម្បីទុកជាឯកសារដល់បុគ្គលិកសិក្សាគ្រប់រូប និងសាធារណជនទូទៅ ដែលយកចិត្តទុកដាក់ក្នុងរឿងសមាគមបុគ្គលិកសិក្សាខ្មែរ ។

ថ្ងៃទី ១៨ វិច្ឆិកា ១៩៧៤

# វគ្គទី ១

# សមាគមបុគ្គលិកសិក្សាខ្មែរ

## ប្រវត្តិសង្ខេប

សមាគមបុគ្គលិកសិក្សាខ្មែរ បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៤៧ ។ ដំបូងឡើយ សមាគមនេះមានឈ្មោះហៅថា « គរុសង្គហៈ » នៃគ្រូខេត្តកណ្ដាលដែលបារាំងហៅថា « MUTUEL DES INSTITUTEURS DE KANDAL ។ បានជាហៅដូចនេះ ពីព្រោះ « គរុសង្គហៈ » មានតែក្នុងខេត្តកណ្ដាលមួយប៉ុណ្ណោះ; រីឯខេត្ត-ក្រុងដទៃទៀតពុំទាន់មាននៅឡើយទេ ។ គោលបំណងធំនៃអង្គការនេះ គឺជួយគ្នាទៅវិញទៅមកទាំងខាងផ្លូវចិត្តទាំងខាងផ្លូវកាយ ( សម្ភារៈ ) ព្រមទាំងរិះរកគ្រប់មធ្យោបាយដើម្បីបង្កើនចំណេះវិជ្ជាជីវៈ នៃសមាជិក-ជិការបស់សមាគម ។ ឆ្នាំបន្ទាប់មកទៀត «គរុសង្គហៈខេត្តកណ្ដាល» ក៏បានលូតលាស់រីកចំរើនធំធាត់ហើយប្រែក្លាយទៅជា គរុសង្គហៈនៃបុគ្គលិកសិក្សា ក្នុងប្រទេសទាំងមូលដែលធ្វើឱ្យបាត់លក្ខណៈតំបន់និយមដើមរបស់ខ្លួន ។ ពេលវេលាចេះតែកន្លងទៅ... ។

ដប់ឆ្នាំក្រោយមក នៅឆ្នាំ ១៩៥៧ មហាសន្និបាតជាប្រវត្តិសាស្ត្រមួយបានបើកសម័យប្រជុំ នៅវិទ្យាល័យស៊ីសុវត្ថិ (បច្ចុប្បន្នវិទ្យាល័យ

ភ្នំពេញ) ។ មហាសន្និបាតនេះ បន្ទាប់ពីប្រជុំអស់ពេលជ័យូរមក (ពីម៉ោង ៨ ព្រឹករហូតដល់ម៉ោង ៥ ល្ងាច) បានសំរេចនូវបញ្ហាសំខាន់ ៗ ដូចតទៅៈ

១- ប្រែឈ្មោះពី គរុសង្គហៈមកជា សមាគមបុគ្គលិកសិក្សាខ្មែរ ។

២- កែប្រែលក្ខន្តិកៈចាស់ ដោយបង្កើតឲ្យមាន គណៈកម្មាធិការកណ្តាលមួយនៅភ្នំពេញ និងគណៈកម្មាធិការក្រុង - ខេត្តនៅតាមក្រុង និងនៅតាមខេត្តនានា ។

៣- ទុកសិទ្ធិសេរីភាពជូលំទូលាយ ជូនគណៈកម្មការខេត្ត - ក្រុង ជាពិសេស ខាងកំណាន់ហិបប្រាក់និងចំណាត់ចំណែងកិច្ចការសមាគមក្នុងខេត្តរៀង ៗ ខ្លួន ។

គួរកត់សំគាល់ថា កាលពីជំនាន់មុន ខេត្ត — ក្រុងមានភារៈត្រឹមតែប្រមូលវិភាគទានពីសមាជិក ហើយផ្ញើវិភាគទានទាំងអស់មកគណៈកម្មាធិការធំនៅឯភ្នំពេញប៉ុណ្ណោះ ។ ហេតុដូចនេះហើយ បានជាមហាសន្និបាតខាងលើចាំមិនភ្លេចទេ នូវពេលដែលគណៈកម្មាធិការគរុសង្គហៈ ផ្ទេរអាណត្តិមកគណៈកម្មាធិការកណ្តាលថ្មី ។ ពេលនោះ គេសង្កេតឃើញនៅសល់ប្រាក់ក្នុងហិបមិនដល់មួយរយរៀលផង បន្ទាប់ពីក្រុមចាស់កាន់កាប់គរុសង្គហៈអស់រយៈពេលដប់ឆ្នាំមក ។ ដំណើរនេះហាក់ដូចជាសមាគមទើបចាប់កំណើតថ្មីដូចនោះដែរ ។

កំណែលក្ខន្តិកៈឆ្នាំ ១៩៥៧ បានជំរុញឲ្យសមាគមបុគ្គលិកសិក្សាមានសន្ទុះលឿនយ៉ាងឆាប់រហ័ស ។ គណៈកម្មាធិការខេត្ត - ក្រុងប្រកប

ដោយស្ម័យភាពទូលំទូលាយ បានបញ្ចេញគំនិតស្ថាបនា គ្រប់បែបយ៉ាង ដែលធ្វើឲ្យសមាគមរីកចំរើន ហើយបានទទួលពីសមាជិកសមាជិកានូវទំនុកទុកចិត្តកាន់តែច្រើនឡើងៗ រៀងរាល់ពេល ។ គណៈកម្មាធិការកណ្ដាល គ្រាន់តែសម្របសម្រួលការងារ និងសកម្មភាពរបស់គណៈកម្មាធិការខេត្ត-ក្រុងនិងធ្វើឱ្យអនុវត្តនូវសេចក្ដីសំរេចរបស់មហាសន្និបាត និងលក្ខន្តិកៈតែប៉ុណ្ណោះ ។ គេគប្បីចាំថា ចាប់ពីឆ្នាំ ១៩៥៧ រហូតមកដល់ឆ្នាំ ១៩៧៤ នេះ ប្រធានគណៈកម្មាធិការកណ្ដាល សុទ្ធតែត្រូវមហាសន្និបាតបោះឆ្នោតរើសតាមលទ្ធិប្រជាធិបតេយ្យដ៏បរិសុទ្ធ ក្នុងក្របខណ្ឌសាស្ត្រាចារ្យទាំងអស់ លើកលែងតែចន្លោះឆ្នាំ ១៩៧០ ៧១ ចេញ ។

នៅឆ្នាំ ១៩៦៧ សមាគមបុគ្គលិកសិក្សាខ្មែរ បានបង្កើតហិបសង្គ្រោះមួយហៅ «បេឡារួម» ដែលជាអង្គការអែបជាប់នឹងសមាគម ដើម្បីផ្ដល់ជំនួយដ៏សមរម្យដល់សមាជិក–ជិកានៅពេលមរណភាព ។ មិនតែប៉ុណ្ណោះ នៅតាមខេត្ត ក្រុង ឬតាមគ្រឹះស្ថានសិក្សា មានបង្កើតគណៈកម្មាធិការផ្សេងៗ ដើម្បីជួយទំនុកបំរុង ឬចាត់ចែងបុណ្យទាន នៅពេលណាដែលសមាជិក–ជិកាមានទុក្ខធុរៈ ។

សកម្មភាពគ្រប់បែបយ៉ាង ជាមួយនឹងភាពស្អាតស្អំ នៃកំណាន់ហិបប្រាក់សមាគម ដើម្បីបំរើផលប្រយោជន៍រួមរបស់បុគ្គលិកសិក្សា បានធ្វើឱ្យសមាគមមានសន្ទុះយ៉ាងលឿន ឆ្ពោះទៅកាន់ការលូតលាស់រីកចំរើនជាពិសេសចាប់ពីឆ្នាំ ១៩៦៧ រហូតមក ។

ក្នុងបច្ចុប្បន្នកាលនេះ សមាគមបុគ្គលិកសិក្សាខ្មែរ នៅជាទីទំនុកទុកចិត្តរបស់សមាជិក-សមាជិកាគ្រប់ៗគ្នាដដែល ដោយគេចង់បានទទួលពីអង្គការនេះនូវសន្តិសុខទាំងខាងផ្លូវអារម្មណ៍ ទាំងខាងផ្លូវសម្ភារៈ ហើយគេម្នាក់ៗ តែងទុកដាក់សមាគមបុគ្គលិកសិក្សាជាអង្គការផ្ទាល់របស់គេផងៗ គេរស់នៅក្នុងមហាគ្រួសារវិជ្ជាជីវៈមួយដ៏ធំ ដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅក្នុងបរិយាកាសប្រកបដោយសាមគ្គីភាព សមភាព និងភាតរភាព ទោះបីគេនៅប្រកបការងារ ក្នុងតំបន់ឆ្ងាយ ៗ ដាច់ស្រយាលពីគេពីឯងក៏ដោយ ៗ គេមានការធានារ៉ាប់រង និងសេចក្តីសង្ឃឹមថា គេមិនស្ថិតនៅតែលតោលឯកោឡើយ ៗ គឺសញ្ចេតនាទាំងនោះហើយ ដែលធ្វើឲ្យគេរឹតតែស្រឡាញ់ការពារសមាគមរបស់គេគ្រប់ពេលវេលា ៗ កិត្តិយសសមាគម មិនមែនគ្រាន់តែជាកិត្តិយស របស់បុគ្គលិកសិក្សាទាំងមូលទេ គឺជាកិត្តិយសរបស់គេផ្ទាល់ថែមទៀតផង ៗ គណៈកម្មាធិការកណ្តាលបន្ត ៗ គ្នា តែងតែនឹកគិតជានិច្ចនូវឧត្តមគតិខាងលើ ហើយសម្របសម្រួលសកម្មភាពឥរិយាបថ ទោះបីមានឧបសគ្គយ៉ាងណាក្តី ដើម្បីរក្សានិងការពារនូវគោលគំនិតទាំងអស់នោះស្របទៅតាមឆន្ទៈរបស់សមាជិក-ជិកា ៗ

តាំងពីឆ្នាំ១៩៧២មក លំដាប់ជីវភាពនៃប្រជាពលរដ្ឋទូទៅដោយឡែកលំដាប់ជីវភាពនៃបុគ្គលិកសិក្សាបានស្រុតធ្លាក់ចុះយ៉ាងសំបើម ៗ រីឯបៀវត្សស្តួចស្តើងរបស់គេផងគ្នា អាចឲ្យគេរស់រានបានដោយក្តីលំបាក ៗ នេះបង្កើតទៅជារឿងសុំរស់ដើម្បីបំពេញករណីយកិច្ច ៗ ចលនាទាមទារ

គម្រើងបៀវត្ស ឲ្យបានស្របតាមការលោតផ្លោះនៃតម្លៃទំនិញ ក៏បានកើតមានឡើង រហូតមកដល់សព្វថ្ងៃនេះ ។ គ្រប់ការទាមទាររបស់បុគ្គលិកសិក្សាពុំទាន់បានដោះស្រាយផង ក៏ស្រាប់តែព្រឹត្តិការណ៍អកុសលមួយបានផ្ទុះឡើង ដោយគេផងទាំងឡាយ ពុំបានចាប់ភ្ញាក់នឹកនាដល់បន្តិចសោះ គឺការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ( ស.ប.ស.ខ. ) កាលពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៧៤ វេលាម៉ោង ១០ យប់ ( តាមសម្លេងវិទ្យុជាតិ ) ។ ការរំលាយនេះបានញាំងសមាជិកជិតរាប់សិបពាន់នាក់ឲ្យមានការស្រឡាំងកាំងតក់ស្លុតនិងខកចិត្តជាអតិបរមា , ហើយបន្ទាប់ពីភាពងុឹងនេះមក គេទាំងឡាយក៏ភ្ញាក់ស្មារតីឡើងវិញ ដោយសំរេចចិត្តប្រកាន់យកអាកប្បកិរិយាមួយដ៏មុឺងម៉ាត់ ប្រកបដោយសេចក្ដីក្លាហានអង់អាច ក្នុងដំណើរតស៊ូរបស់គេទៅមុខទៀត ពីព្រោះគេយល់ច្បាស់ថា ការរស់ឬស្លាប់នៃសមាគមរបស់ខ្លួន ពុំមែនអាស្រ័យលើនរណាក្រៅពីកម្លាំងរួមនៃបុគ្គលិកសិក្សានោះឡើយ ហើយម្យ៉ាងទៀតគេយល់ឃើញថា គេមិនចង់ឲ្យសមាគមប្រជាធិបតេយ្យមួយក្លាយ ទៅជាសគមទាសភាពនៃក្រុមបុគ្គលឡើយ ។

# ខណ្ឌទី ២

# អាជ្ញាធររាតត្បាតទីស្នាក់ការនៃសមាគមបុគ្គលិកសិក្សាខ្មែរ

ព្រឹត្តិការណ៍កើតឡើងមុនពេល និងក្នុងពេលរំលាយសមាគមបុគ្គលិក-សិក្សាខ្មែរ បានប្រព្រឹត្តទៅយ៉ាងឆាប់រហាស់ ៗ ថ្ងៃពុធ ទី ២៥ កញ្ញា ១៩៧៤ វេលាម៉ោងប្រាំភ្លឺ អាជ្ញាធរមួយក្រុមប្រមាណជា ២០ នាក់ ចំរុះដោយក្រុមនគរបាលជាតិ ក្រុមអាវុធហត្ថនិងខាងតុលាការសឹក បានជិះរថយន្តមកឈប់នៅមុខទីស្នាក់ការសមាគម, លេខ ៥. វិថីឧកញ៉ាម៉ែន, ភ្នំពេញ ៗ បន្ទាប់មកក្រុមខាងលើបានសួររកអ្នកទទួលខុសត្រូវនៅទីនោះ តែគ្មានឃើញ ៗ ទីស្នាក់ការដែលជាទីផ្ទះសំណាក់ផង មានតែឆ្មាំម្នាក់ចាំយាមនៅពេលយប់ ៗ ក្រុមអាជ្ញាធរដដែល កំគាស់ទ្វារចូលទៅក្នុងការិយាល័យហើយគាស់សោទូ តុ ប៊ុយរ៉ូ ទាំងអស់ ចាប់រើរុសឆែកឆេរខ្ទេចខ្ទី គ្មានសល់ក្រឡុកក្រលៀតត្រង់ណាឡើយ ៗ រួចមកគេក៏ប្រមូលយកគ្រឿងសម្ភារៈការិយាល័យសំណុំលិខិតផ្សេងៗរបស់សមាគម ផ្ញើនដាក់ឡានទ្រុងដែលគេយកមកចតចាំបំរុងជាស្រេចនៅមុខទីស្នាក់ការ ៗ

នៅម៉ោង ០៧ ម ០០ ក្រុមអាជ្ញាធរខាងលើបានបញ្ចប់បេសកកម្មហើយក៏បានវិលត្រឡប់ទៅវិញដោយនាំខ្លួនមនុស្ស ៤ នាក់ទៅជាមួយផងគឺ ៖

— លោកអ៊ុំខ អ៊ុត, សមាជិកគណៈកម្មាធិការកណ្ដាល ដែលស្នាក់នៅទីនោះ,

— លោក ញឹក ឃួន គ្រូបឋមសិក្សា មកស្នាក់នៅទីនោះ ,

— លោក ទ្រី — " —

— លោក តាត អ៊ី ធ្មប់ជិសណ្ដារមណ្ឌល,

ឯលោក ចាំ ចុំា សមាជិកគណៈកម្មាធិការកណ្ដាល ក៏ត្រូវអាជ្ញាធរចាប់នៅឯផ្ទះលោកនៅព្រឹកថ្ងៃដដែលនេះដែរ ។

គួររំលឹកឡើងវិញបន្តិចថា លោក ញឹក ឃួន និង លោក ទ្រី បានត្រូវក្រសួងមានសមត្ថកិច្ចដោះលែងនៅថ្ងៃដដែលវេលាម៉ោង ១២ ។

នៅម៉ោង ៩ ព្រឹកថ្ងៃនោះ គណៈកម្មាធិការកណ្ដាលបានចេញសេចក្ដីប្រកាសជូនពត៌មានមួយដូចតទៅ :

# សេចក្តីជូនដំណឹង
## ពីសមាគមបុគ្គលិកសិក្សាខ្មែរ

គណៈកម្មាធិការកណ្តាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ សូមប្រកាសជូនពត៌មានដល់គ្រប់សមាជិក - សមាជិកា នៃសមាគម ព្រមទាំងដល់សាធារណជនថា នៅថ្ងៃទី ២៥ កញ្ញា ១៩៧៤ វេលាម៉ោងប្រាំភ្លឺ មានកងអាវុធហត្ថ និងភ្នាក់ងារនៃក្រសួងមានសមត្ថកិច្ចមួយចំនួនធំបានលួចរំលោកចូលទៅក្នុងការិយាល័យនៃទីស្នាក់ការរបស់សមាគម ស្ថិតនៅ លេខ ១៥, វិថីឧកញ៉ាម៉ែន, ភ្នំពេញ ។ បន្ទាប់ពីបានរុះរើគាស់តុ ទូ ដកលក់ឯកសារសមាគម ដោយគ្មានវត្តមាននៃអ្នកទទួលខុសត្រូវរបស់សមាគមនៅទីនោះមក ក្រុមអាជ្ញាធរខាងលើបានលួចយកឯកសារសម្ភារៈនិងវត្ថុដទៃទៀតមួយចំនួនធំរបស់សមាគម ។ យើងកំពុងតែឱ្យស្រង់បញ្ជីជូនពត៌មានជាក្រោយ ។

ការប្រព្រឹត្តិរបស់ក្រុមអាជ្ញាធរខាងលើ មកលើទីស្នាក់ការរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ជាការរំលោភមួយយ៉ាងសាហាវទៅលើសិទ្ធិសេរីភាពនៃប្រជាពលរដ្ឋ សេរីភាពខាងលំនៅស្ថាន រំលោភដោយចំហរលើរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋ ។

គណៈកម្មាធិការកណ្តាល តម្រូវឱ្យក្រសួងមានសមត្ថកិច្ចសងមកសមាគមវិញ នូវឯកសារ សម្ភារៈទាំងអស់ ដែលត្រូវបានបប្ជូនទៅចំកណ្តាលក្រុងនេះ ព្រមទាំងទម្លាក់ទំនួលខុសត្រូវទាំងស្រុងទៅលើអាជ្ញាធរខាងលើ

ចំពោះកម្មវិបាកគ្រប់បែបយ៉ាងដែលនឹងកើតចេញពីអំពើហ្វាស៊ិសខាងលើ ។

សេចក្ដីជូនពត៌មាននេះ សូមសមាជិក - សមាជិកា និងមហាជនមេត្តាជ្រាប ។

*ភ្នំពេញ. ថ្ងៃទី ២៥ កញ្ញា ១៩៧៤*

គណៈកម្មាធិការកណ្ដាល

នៅវេលាម៉ោង ២១ តាមវិទ្យុជាតិ រដ្ឋាភិបាលបានផ្សាយពត៌មានអំពីការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ដោយមានក្រឹត្យចែងពីការរំលាយនេះទៀតផង ។ ខាងក្រោមនេះជាក្រឹត្យរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ជាភាសាជាតិនិងភាសាបារាំង :

## សាធារណរដ្ឋខ្មែរ

លេខ ៦៣២ - ៧៤ . បស១

## ក្រឹត្យ

ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ

បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ

បានឃើញក្រឹត្យលេខ ៤៧៤ - ៧៤. បស១ ចុះថ្ងៃទី ១៦ មិថុនា ១៩៧៤ កែប្រែដោយអត្ថបទជាបន្តបន្ទាប់ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី

បានឃើញបញ្ញត្តិលេខ ១១១ ចុះថ្ងៃទី ៣១ ធ្នូ ១៩២៦ ពីបទបញ្ញត្តិទាំងឡាយនៃសមាគម

### គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

### បង្គាប់ដូចខាងក្រោមនេះ

*ប្រការមួយ.—* ត្រូវរំលាយចោលចាប់ពីថ្ងៃចុះហត្ថលេខាលើក្រឹត្យនេះ នូវសមាគមបុគ្គលិកសិក្សាខ្មែរ ដែលត្រូវបានទាន់ជាក់ស្តែង ថាបានធ្វើអំពើវិទ្ធង្សនាប្រឆាំងសាធារណរដ្ឋ ជាប្រយោជន៍ដល់ខ្មាំង ។

*ប្រការពីរ* – រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កំណែនទូទៅ សន្តិភាវកម្ម សន្តិសុខ និងធម្មការ ត្រូវទទួលភារៈចាត់ការឲ្យបានសំរេចតាមក្រិត្យនេះ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ១៩៧៤*

ហត្ថលេខា : **លន់ នល់**

ទទួលបញ្ជាលោកប្រធានាធិបតី

រដ្ឋមន្ត្រីទីមួយស្តីទី

ហត្ថលេខា : **ប៉ាន់ សុធី**

បានចំឡងសំរាប់ចែក

អគ្គលេខាធិការនៃរដ្ឋាភិបាល និង គ.ប.

ហត្ថលេខា : កញ្ញា **សៀវ ណាយ**

បានដាក់ជូនសុំហត្ថលេខា

ប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ

ដោយ

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កំណែនទូទៅ

សន្តិភាវកម្ម សន្តិសុខជាតិ និង ធម្មការ

ហត្ថលេខា : **ឯក ប្រឿង**

# REPUBLIQUE KHMERE

## COMMUNIQUE DU GOUVERNEMENT

Le gouvernement a l'honneur de porter à la connaissance du public que pendant ces derniers temps certains membres du comité central de l'AMCEK ont entrepris des activités subversives contre la Républipue afin d'y semer le désordre et les destructions. A cet égard, la déclararation du 23 septembre écoulé ne visant autre que la provocation au désordre et au meutre, est édifiant. C'est ainsi que le gouvernement, à la lumière des renseignements fournis à temps par des personnalités loyales, a pris des mesures afin qu'une perquisition selon les formes légales fût entreprise le 25 septembre sous le contrôle direct du tribunal militaire aux armées. Elle a permis la découverte et la confiscation de 203 exemplaires de déclaration en khmer et de 239 exemplaires en anglais ainsi que 3 machines à écrire à caractère français, un ronéo et d'autres objets destinés à la suversion. Tous ces documents et objets constituent des preuves évidentes de subversion contre le régime républcain.

Ces actes subversives commises par certains membres du comité central de cette association n'étaient nullement les première, Tels étaient, en effet, les cas de la réunion illégale du 27 juillet dernier et de l'émission non moins illégale des déclarations qui avaient provoqué le meurtre de nos deux hautes personnalités.

C'est sous la menace des activités qui pourraient engendrer des dangers graves contre le régime républicain,

que le gouvernement a décidé de prendre des mesures nécessaires en vue de maintenir l'ordre et la sécurité endécidant de résoudre l'AMCEK à partir du 25 septembre par le Kret n°- 632/74/PRK du 25/9/74.

L'administration des biens de l'association sera confiée à un comité spécial nommé par le ministère de l'Education nationale, dont les membres sont choisis parmi les personnalités dont les sentiments républicains sont hors de doute. Ce comité se chargera de liquider les biens de l'association.

*Phnom Penh, le 25 Septembre 1974*

DISSOLUTION DE L'AMCEK

LE PRESIDENT DE LA REPUBLIQUE KHMERE

. . . . . . . . . . . . . . . . . . . .

**DECRETE :**

*ARTICLE 1er.* – Est dissoute, à compter de la date de la signature du présent kret, l'AMCEK prise en flagrant délit d'actions subversives anti-républicaines en faveur de l'ennemi.

*ARTICLE 2.* – Le ministre de l'Intérieur, de lamobilisation générale, de la Sécurité et des Cultes est ehargé de l'exécution du présent kret.

*Fait a Phnom Penh, le 25 Septembre 1974*
*Signé : LON NOL*

ស្អែកឡើងថ្ងៃទី ២៦ កញ្ញា ១៩៧៤ គណៈកម្មាធិការកណ្ដាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ បានចេញប្រកាសជូនដំណឹងលេខ ២ ដូចខាងក្រោមនេះ ៖

# ប្រកាសជូនដំណឹង លេខ ២
# នៃសមាគមបុគ្គលិកសិក្សាខ្មែរ

គណៈកម្មាធិការកណ្ដាល នៃ សមាគមបុគ្គលិកសិក្សាខ្មែរ សូមប្រកាសជូនដំណឹងដល់សមាជិក-ជិកា និង សាធារណជនថា អាជ្ញាធរមានសមត្ថកិច្ច បន្ទាប់ពីបានរំលោភចូលឆែកឆេរ រឹបយកឯកសារ និងសំភារៈការិយាល័យអស់ពីទីស្នាក់ការសមាគម ស្ថិតនៅលេខ ៥ វិថីឧកញ៉ាម៉ែន កាលពីថ្ងៃទី ២៥ ខែកញ្ញា ១៩៧៤ បានប្រកាសរំលាយសមាគមបុគ្គលិកសិក្សា កាលពីថ្ងៃទី ២៥ ខែកញ្ញា ១៩៧៤ វេលាម៉ោង ២២ យប់ ។

បុព្វហេតុនៃការរំលាយសមាគម ដែលមានអាយុជិតសាមសិបឆ្នាំ ហើយដែលជាអង្គការសង្គមកិច្ចមួយដ៏ធំរបស់គ្រូ គណៈកម្មាធិការកណ្ដាលពុំទាន់បានដឹងនៅឡើយ ។ គណៈកម្មាធិការកណ្ដាល នឹងព្យាយាមតាមដានកិច្ចការនេះតទៅទៀត ។

អាស្រ័យហេតុនេះ សូមសមាជិក-ជិកានិងសាធារណជនមេត្តាជ្រាប ។

*ភ្នំពេញ, ថ្ងៃទី ២៦ ខែកញ្ញា ១៩៧៤*

នៅថ្ងៃដដែល គណៈកម្មាធិការកណ្តាលបានសរសេរលិខិតរាំមួយទៅលោករដ្ឋមន្ត្រីទី ១ ស្តីទី ដែលមានអត្ថបទទាំងស្រុងដូចខាងក្រោមនេះ៖

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្តាល
លេខ ៧៤ - ៥១៤ គក - ល

**សាធារណរដ្ឋខ្មែរ**

ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា គ.ស. ១៩៧៤

គណៈកម្មាធិការកណ្តាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ
សូមជំរាបលោករដ្ឋមន្ត្រីទី ១ ស្តីទី

**កម្មវត្ថុ :** ការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ។

ខ្ញុំសូមជំរាបលោករដ្ឋមន្ត្រីទី ១ ស្តីទីថា សមាគមបុគ្គលិកសិក្សាខ្មែរ ដែលមានអាយុជិតសាមសិបឆ្នាំមកទល់នឹងថ្ងៃនេះ ហើយដែលជាអង្គការសង្គមកិច្ចមួយដ៏ធំរបស់គ្រូ តែងផ្តល់ទិនផលដល់សមាជិក-ជិកានូវសន្តិសុខទាំងខាងផ្លូវចិត្ត ទាំងខាងផ្លូវសង្គម ទាំងខាងផ្លូវសំភារៈគ្រប់បែបយ៉ាង ។ គ្រូគ្រប់រូបតែងផ្ញើសេចក្តីសង្ឃឹមរបស់គេលើអង្គការរបស់គេនេះ ។

ការរំលាយសមាគមក្នុងពេលនេះ ទុកជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ហើយការរំលាយដោយបង្ខំមកពីអាជ្ញាធរ ជាការរំលោភលើសិទ្ធិសេរីភាព ដែលរដ្ឋធម្មនុញ្ញសាធារណរដ្ឋបាន

ធានារ៉ាប់រងដល់គ្រប់ពលរដ្ឋ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោករដ្ឋមន្ត្រីទី ១ ស្តីទី មេត្តាពិនិត្យរឿងហេតុនេះឡើងវិញជាបន្ទាន់ ឬអនុញ្ញាតច្បាប់ជាពិសេសដើម្បីកោះហៅមហាសន្និបាតវិសាមញ្ញ ដើម្បីទុកឱ្យអង្គការខាងក្រោយនេះប្រកាសរំលាយខ្លួនគេស្របទៅតាមប្រការ ៥៦, ៥៧, ៥៨ នៃលក្ខន្តិកៈសមាគម ។

ខ្ញុំមានជំនឿថា លោករដ្ឋមន្ត្រីទី ១ ស្តីទី មុខជាមានការយល់ដ៏ច្បាស់អំពីបញ្ហានេះ ព្រមទាំងអនុញ្ញាតច្បាប់ធ្វើមហាសន្និបាតក្នុងពេលដ៏គួរ ដើម្បីដោះស្រាយបញ្ហារួមគ្នា ។

សូមលោក រដ្ឋមន្ត្រីទី១ស្តីទី មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅនៃខ្ញុំ ។

ចំលងជូន :

- ខុទ្ទកាល័យប្រធានាធិបតី
- សភាទាំងពីរ
- គ្រប់គណៈកម្មាធិការខេត្ត-ក្រុង នៃសបសខ
- ឯកសារ

ជ- គណៈកម្មាធិការកណ្តាល

ប្រធាន

ហត្ថលេខា : ម៉ៃ លន់

ទីស្ដីការរដ្ឋមន្ត្រីទីមួយ

**សាធារណរដ្ឋខ្មែរ**

លេខ 1525 អល-រប ១-គឧប - 66

ភ្នំពេញ, ថ្ងៃទី 15 ខែ តុលា ១៩៧៤

**រដ្ឋមន្ត្រីទីមួយ**

ជំរាបមកលោកប្រធានគណៈកម្មាធិការកណ្ដាល

នៃអតីតសមាគមបុគ្គលិកសិក្សាខ្មែរ

ភ្នំពេញ

**កម្មវត្ថុ** : ការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ។

**យោង** : លិខិតលេខ ៧៤-៥១៤-គក-ល នៃសមាគមបុគ្គលិកសិក្សាខ្មែរ ។

តតាមកម្មវត្ថុដូចមានយោងខាងលើនេះ ខ្ញុំសុំជំរាបលោកថា ការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ បានត្រូវធ្វើឡើងស្រប តាមលក្ខណៈច្បាប់ ក្នុងគោលគំនិតរក្សាសន្តិសុខជាតិនិងរបៀបរៀបរយសាធារណៈ ។ ដើម្បីផ្ដល់នូវធានាដល់គ្រូគ្រប់រូប នូវសន្តិសុខខាងផ្លូវចិត្តខាងផ្លូវសង្គម និងខាងផ្លូវសម្ភារៈគ្រប់បែបយ៉ាង រដ្ឋាភិបាលក៏បានបង្កើតមូលនិធិសង្គមកិច្ចបុគ្គលិកសិក្សារួចហើយដែរ ។

អាស្រ័យហេតុនេះ ខ្ញុំយល់ឃើញថាគ្មានការចាំបាច់នឹងធ្វើមហាសន្និបាតទេ ព្រោះសមាគមបានត្រូវរំលាយទៅហើយ ។

ហត្ថលេខា : **ប៉ាន់ សុធី**

នៅថ្ងៃទី ២៧ កញ្ញា ១៩៧៤ គណៈកម្មាធិការបានដាក់ពាក្យបណ្ដឹងទៅក្រុមវិវាទ ស្ដីពីការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ដោយខុសលក្ខណៈច្បាប់ និងល្មើសនឹងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ ។ រីឯលិខិតប្ដឹងនេះមានន័យទាំងស្រុងដូចតទៅ:

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្ដាល
លេខ ៧៤ - ៥១៥ គក - ល

**សាធារណរដ្ឋខ្មែរ**

ភ្នំពេញ, ថ្ងៃទី ២៧ ខែកញ្ញា ១៩៧៤

ប្រធានគណៈកម្មាធិការកណ្ដាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ

សូមជំរាបលោកចាងហ្វាងសាលាក្រុមវិវាទ
ភ្នំពេញ

**កម្មវត្ថុ:** បណ្ដឹងពីការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ
**យោង:** ក្រឹត្យលេខ ៦៣២ - ៧៤ បសខ ចុះថ្ងៃទី ២៤-៩-៧៤

ខ្ញុំសូមជំរាបលោកចាងហ្វាងថា តាមក្រឹត្យលេខ ៦៣២ - ៧៤ - បសខ ចុះថ្ងៃ២៥ -៩- ៧៤ រដ្ឋាភិបាលបានប្រកាសរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ដែលជាអង្គការមួយត្រូវបានបង្កើតឡើង តាមលក្ខណៈច្បាប់ត្រឹមត្រូវ ហើយដែលមានការធានារ៉ាប់រងពីរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋផងទៀត ។

វិធានការរបស់រដ្ឋាភិបាល បានអនុវត្តល្មើសនឹងច្បាប់ផង ហើយធ្វើឲ្យសមាជិក-ជិកាចំនួនម្ភៃប្រាំពាន់នាក់ មានក្ដីរំភើបញាប់ញ័រចំពោះការបាត់នូវអត្ថការមួយ ដែលតែងផ្ដល់ដល់គេផងគ្នា នូវការសង្ឃឹម កំណាក់ក្ដៅ ការធានារ៉ាប់រងសន្តិសុខខាងផ្លូវចិត្ត ផ្លូវសំភារៈ និងផ្លូវសង្គម ។

អាស្រ័យហេតុនេះ ខ្ញុំសូមធ្វើពាក្យតាងនាមសមាជិក-ជិកាទាំងអស់ចូលមកលោកចាងហ្វាង ដើម្បីសូមលោកមេត្តារកយុត្តិធម៌ ជូនសមាជិកសមាគម ដោយតំរូវឲ្យរដ្ឋាភិបាលទុកជាមោឃៈ នូវក្រិត្យរំលាយសមាគម ព្រមទាំងឲ្យសមាគមបុគ្គលិកសិក្សាខ្មែរ រស់រានមានសកម្មភាពតទៅទៀត ។

សូមលោកចាងហ្វាងមេត្តាទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅនៃខ្ញុំ ។

ហត្ថលេខា : **ម៉ៃ លន់**

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

បញ្ជូនមកគ្រប់គណៈកម្មាធិការខេត្ត-ក្រុង នៃសបសខ

ដើម្បីជ្រាបជាពត៌មាន ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែកញ្ញា ១៩៧៤

អគ្គលេខាធិការរងនៃសបសខ.

**អួន ធុល**

នៅថ្ងៃដដែលនេះដែរ យើងចាប់បានទូរលេខ ១ ច្បាប់ ដែលក្រសួងអប់រំបានវាយផ្សាយបញ្ជូនទៅចាត់តាំងគណៈកម្មការក្រុង-ខេត្ត ដូចតទៅ :

REPUBLIQUE KHMERE

DEPARTEMENT
de
l'Education Nationale

TELEGRAMME OFFICIEL
N° 52-Cab/IP

Phnom-Penh, le 27 Septembre 1974

MINEDUCATION
à INSPRIMAIRES ET DIRPROVINCIAUX
ET MUNICIPAUX
En Cion à tous Aphibals Krung et Khèt

Par suite dissolution AMCEK Honneur vous prier vous concerter pour créer par désignation un Comité provincial ou municipal provisoire composé de cinq membres dont vous êtes Président et Vice-Président pour continuer activités Ex.Bélaruom Stop Instructions détaillées suivant Stop obliger percevoir cotisation mensuelle et envoyer secours décès à Monsieur TENGYOUVONG Minéducation stop et fin.

P. le Premier Vice Premier Ministre,
Ministre de l'Education et des Relations
avec le parlement,
*Le Sous-Secrétaire d'Etat,*
*Signé : KAU LON*

Chapitre 67-Art. 2- yk
Service expéditeur : Mineducanale teleph. 2-3525
Service liquidateur: signé : Ing Yuk Heang

MINISTERE
DE
L'EDUCATION

REPUBLIQUE KHMERE

N° 567/9S.

## DECISION MINISTERIELLE

LE PREMIER VICE-PREMIER MINISTRE, MINISTRE DE L'EDUCATION ET DES RELATIONS AVEC LE PARLEMENT

Vu la Constitution de la République Khmère :

Vu le Kret n° 474/74-PRK du 15 Juin 1974. modifié par les textes subséquents portant nomination du Cabinet Ministériel :

Vu le Kret n° 632/74-PRK du 25 Septembre 1974 portant dissolution de l'AMCEK :

Vu le Procès Verbal de la réunion d'un groupe d'Enseignants en date du 27 Septembre 1974:

DECIDE :

ARTICLE Ier.- Il est institué un comité dénommé «Comité Provisoire de Gestion du Fonds Social du Corps Enseignant" et composé de :

M. NOP CHHOM, Inspecteur de l'Enseignement primaire retraité . . . . . . . . Président

M. MEN CHHUM, Inspecteur de l'Enseignement primaire retraité. . . . . . . Ier Vice Président

M. PANH LAUV, Inspecteur de l'Enseignement primaire retraité . . . . . 2è Vice Président

M. CHHOY VY, Professeur de l'Enseignement Secondaire . . . . . . Secrétaire Général

M. TAU HING, Inspecteur de l'Enseignement Primaire . . . . 1er Sécrétaire Général Ajt.

M. CHHUON THUCH, Instituteur de l'Enseignement Primaire . . . . . 2è Secrétaire Général Ajt.

M. TENG YOUVONG, Inspecteur de l'Enseignement Primaire . . . . . Trésorier Général

M. MAING MORY, Inspecteur de l'Enseignement Primaire , , , , 1er trésorier Général Ajt.

Mme SOK PHAT, Instritutrice de l'Enseignement Primaire . . . . 2è Trésorier Général Ajt.

M. KHVANN SIPHAN, Profosseur de l'Ens. Second. retraité . . . . . . . Commissaire

M. THACH BA, Prof. de l'Ens. Sec. 1er cycle retraité -id-

M. BUN PHUNG, Inspecteur de l'Ens. Primaire retraité -id-

M. PHAY PHENG, Inspecteur de l'Ens. Primaire -id-

Mme YAO MALAING, Inspectrice de l'Ens. Primaire -id-

Mme IN RON, Prof. de l'Ens. Secondaire, 1er cycle -id-

ARTICLE 2.- Le dit Comité a son siège provisoire au Ministère de l'Ebucation.

ARTICLE 3.- Le Chef de Cabinet du Ministère de l'Education est chargé de l'exécution de la présente Décision Ministérielle.

*Phnom-Penh, le 11 Octobre 1974*
Signé : *PAN SOTHI*

**DESTINATAIRES :**
- Cab/PRK-AN- Sénat
- Département du Premier Ministre-JGG-JOC
- Tous Ministères
- Toutes Universités
- DGE
- Toutes Directions relevant du Minéducation
- Tous Bureaux du Minéducation
- Minéducation : Cab- ID - SGCSU - DB
- Tous Membres du Comité Provisoire de Gestion du Fonds Social du Corps Enseignant
- Archives et Bibliothèque Nationale

នៅថ្ងៃទី ១ តុលា ១៩៧៤ យើងបានទទួលដំណឹងពីធនាគារនានាមកថា គណនីទាំងឡាយរបស់ ស.ប.ស១. បានត្រូវអាជ្ញាធរបង្គាប់ឲ្យផ្អាកសកម្មភាពសិន ៗ ជាបន្ទាន់ គណៈកម្មាធិការកណ្តាលក៏បានចាត់វិធានការបន្ថែមដើម្បីថែរក្សាទ្រព្យសម្បត្តិរបស់សមាគម ក្នុងរយៈពេលចន្លោះនេះ ព្រោះកាលនៅថ្ងៃទី ២៦ ខែ តុលា ១៩៧៤ គណកម្មាធិការកណ្តាលបានសរសេរលិខិតទៅធនាគារនានា ដែលសមាគមមានគណនីដើម្បីសុំឲ្យអ្នកទទួលខុសត្រូវទាំងនោះចាត់វិធានការរក្សាលុយកាក់សមាគមឲ្យបានគង់វង្សរួចទៅហើយ ។ឯលិខិតនោះគឺ :

*Phnôm Penh, le 26 Septembre 1974*

N° 01/74/CC/X

A MONSIEUR LE PRESIDENT DIRECTEUR GENERAL
DE LA BANQUE KHMERE POUR LE COMMERCE,

DE l'INADANA JATI,

A Monsieur le Trésorier Général

PHNOM-PENH.

MONSIEUR,

J'ai l'honneur de vous faire connaître qu'à la suite de la dissolution de l'Association des Membres du corps Enseignant Khmer (AMCEK), seuls le Président et le Trésorier du comité central ( M.M. Mai Lon et Kuoch-Kyléng ) dûment mandatés par l'Assemblée Genérale, ont habilité à gérer les fonds (opérations de dépôt, de retrait, de virement ou de transfert . . ) déposés dans votre Etablissement : comptes n° . . . .

Je vous saurais donc gré quant aux mesures et dispostions à prendre en opposant un refus à toutes opérations sur les comptes plus haut mentionnés faites par des personnes ou organisme tierces non légalement mandatés par l'Association.

Avec mes remerciements anticipés, veuillez croire, Monsieur le Président Directeur Général, à l'assurance de mes sentiments les meilleurs./-

MAI LON
Président du Comité
Central de l'AMCEK

នៅថ្ងៃទី ៥ តុលា ១៩៧៤ លិខិតមួយត្រូវបានផ្ញើទៅលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីស្នើសុំសម្ភារៈនិងសំណុំលិខិតផ្សេងៗ ដែលក្រសួងមានសមត្ថកិច្ចបានរឹបអូសយកកាលពីថ្ងៃទី ២៥ កញ្ញា ១៩៧៤ ដែលមានដូចខាងក្រោមនេះ :

សមាគមបុគ្គលិកសិក្សាខ្មែរ
លេខ ៥១ វិថីឧកញ៉ា ម៉ែនភ្នំពេញ
លេខ ០៣-៧៤ គក

**សាធារណរដ្ឋខ្មែរ**

ភ្នំពេញថ្ងៃទី១៥ ខែតុលា គ.ស. ១៩៧៤

ប្រធានគណៈកម្មាធិការកណ្តាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ

សូមជំរាបលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**កម្មវត្ថុ:** សំណើសុំឯកសារផ្សេងៗ និងសំភារៈរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ដែលត្រូវអាជ្ញាធរមានសមត្ថកិច្ចរឹបអូស ។

ខ្ញុំសូមជំរាបលោករដ្ឋមន្ត្រីថា កាលពីថ្ងៃទី ២៥ កញ្ញា ១៩៧៤ វេលាម៉ោងប្រាំភ្លឺ ក្រសួងមានសមត្ថកិច្ច បន្ទាប់ពីបានចូលឆែកឆេរទីស្នាក់ការសមាគម ស្ថិតនៅលេខ ៥ វិថីឧកញ៉ាម៉ែន ភ្នំពេញ បានរឹបអូសយកសំភារៈមួយចំនួន " ដូចមានបញ្ជីភ្ជាប់មកជាមួយនេះ " និងលិខិត និងសំណុំលិខិតជាច្រើន ដែលទាក់ទងនឹងដំណើរការ

សមាគម ។ សំភារៈទាំងនេះ ជាសំបាត់ផ្ទាល់របស់សមាគម ដែលគណៈកម្មាធិការកណ្តាល មានភារៈថែរក្សាកុំឲ្យបាត់បង់ ព្រមទាំងសំរាប់ប្រើប្រាស់ជាផលប្រយោជន៍នៃសមាគមផង ។

អាស្រ័យហេតុនេះ ខ្ញុំសូម.លោករដ្ឋមន្ត្រីមេត្តាបញ្ជាឲ្យក្រសួងមានសមត្ថកិច្ច ប្រគល់ជូលសមាគមវិញ នូវសំភារៈ និងលិខិតផ្សេង ៗ ដូចបានជំរាបខាងលើ ។

ដោយមានជំនឿលើការយោគយល់របស់លោករដ្ឋមន្ត្រី ខ្ញុំសូមលោកមេត្តាទទួលនូវគារវភក្តិដ៏ស្មោះនៃខ្ញុំ ។

ចំលងជូន:

- លោកអនុរដ្ឋលេខាធិការ នៃ ក្រសួងសន្តិសុខជាតិ
- គ្រប់គណៈកម្មាធិការខេត្ត-ក្រុង នៃ ស.ប.ស.ខ.
- ឯកសារ ។

ហត្ថលេខា: **ម៉ៃ លន់**

កាលពីប៉ុន្មានថ្ងៃមុននេះ សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាល និងសុន្ទរកថារបស់លោក ណុប ឆុំ ស្ដីពីការរំលាយសមាគមបុគ្គលិកសិក្សា-ខ្មែរ និងការបង្កើតមូលនិធិសង្គមកិច្ចបុគ្គលិកសិក្សា ដែលធ្វើឲ្យមតិបុគ្គលិកសិក្សានិងសាធារណជនយល់ច្រឡំខ្លះនោះ គណៈកម្មាធិការកណ្ដាលបានធ្វើសេចក្ដីបញ្ជាក់មួយជូនតទៅ :

## សេចក្ដីបញ្ជាក់

## ពីគណៈកម្មាធិការកណ្ដាលនៃសមាគមបុគ្គលិកសិក្សាខ្មែរ

សមាគមបុគ្គលិកសិក្សាខ្មែរ " ស-ប-ស-ខ- " សូមបញ្ជាក់ជូនសមាជិក-សមាជិកា និងសាធារណជនថា " កាលពីថ្ងៃទី ២៥ កញ្ញា ១៩៧៤ វេលាម៉ោង ៩ ព្រឹក ក្រុមអាជ្ញាធរបានចូលឆែកឆេរទីស្នាក់ការរបស់សមាគម ស្ថិតនៅលេខ ៥, វិថីឧកញ៉ា ម៉ែន " ។ ការឆែកឆេរនេះ បានប្រព្រឹត្តទៅដោយឥតមានអ្នកទទួលខុសត្រូវនៃសមាគមចូលរួមផងទេ ។ នៅពេលនោះ ក្រុមអាជ្ញាធរបានរឹបយក :

- ម៉ាស៊ីនអង្គុលីលេខ ៣
- ម៉ាស៊ីនរ៉ូណេអូ ១
- ត្រាសមាគម ត្រាឈ្មោះប្រធាន និង ឈ្មោះអគ្គហិរញ្ញិក
- សេចក្ដីថ្លែងការណ៍ជាភាសាជាតិនិងភាសាអង់គ្លេសមួយចំនួន

— កំណត់ហេតុនៃមហាសន្និបាត កំណត់ហេតុនៃការប្រជុំគណៈកម្មាធិការកណ្ដាល ។ល។

— លិខិតឆ្លើយឆ្លងរវាងគណៈកម្មាធិការកណ្ដាលនិងគណៈកម្មាធិការខេត្ត-ក្រុង ដែលទាក់ទងនឹងដំណើរការសមាគម

— សៀវភៅកត់លិខិតចូល - ចេញ ។ល។

គឺសំភារៈ និង ប្រដាប់ប្រដាទាំងនេះហើយ ដែលអាជ្ញាធរចាត់ទុកជា " ឯកសារវិទ្ធង្សនា" ។

គណៈកម្មាធិការកណ្ដាលសូមជំរាបថា ម៉ាស៊ីនខាងលើ គឺមានមកយូរហើយតាំងពីឆ្នាំ ១៩៦៧ ម្ល៉េះ ហើយប្រើប្រាស់មិនគ្រប់គ្រាន់ផង បើគេដឹងថា ការិយាល័យនៃគណៈកម្មាធិការកណ្ដាលមានទំហំការងារស្មើនឹងនាយកដ្ឋានមួយនៃក្រសួងអប់រំ " សមាជិកជាងពីរម៉ឺននាក់" ។ ឯសេចក្ដីថ្លែងការណ៍វិញ គឺមានចុះកាលបរិច្ឆេទដាក់អាសយដ្ឋាន ពោះត្រាគណៈកម្មាធិការកណ្ដាលគ្រប់គ្រាន់ ពុំមែនជាលិខិតសំងាត់ អនាមិក ឬ ខិតប័ណ្ណអ្វីសោះទេ ។ មិនតែប៉ុណ្ណោះ គ្រប់លិខិតដែលអាជ្ញាធរប្រមូលយកទៅនោះ សុទ្ធតែលិខិតត្រឹមត្រូវ មានលេខ មានកាលបរិច្ឆេទ អាសយដ្ឋាន គឺ មិនមែន " ឯកសារវិទ្ធង្សនា " ឡើយ ។

ម្យ៉ាងទៀតគណៈកម្មាធិការកណ្ដាលសូមជូនជាពត៌មានបន្ថែមទៀតថា ការប្រជុំគណៈកម្មាធិការកណ្ដាលនាថ្ងៃទី ២៧ កក្កដា ១៩៧៤ ដែល

អាជ្ញាធរប្រកាសថាជា "ការប្រជុំឥតច្បាប់" នោះ ការពិតគឺមិនមែនដូច្នោះទេ ។ ការប្រជុំនោះ គឺ បានប្រព្រឹត្តទៅនៅក្នុងសាលសន្និសីទនៃទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ បន្ទាប់ពីបានអនុញ្ញាតច្បាប់ពីលោករដ្ឋមន្ត្រីក្រសួងនេះមក ។ គណៈកម្មាធិការកណ្ដាលបានអញ្ជើញលោកនាយខុទ្ទកាល័យឲ្យចូលរួមប្រជុំផងដែរ តែលោករវល់ពេកលោកក៏ចាត់ឲ្យនាយការិយាល័យ នៃកិច្ចការនយោបាយក្រសួងអប់រំចូលប្រជុំជំនួស ។

ចំពោះសេចក្តីថ្លែងការណ៍ទាំងឡាយ ដែលក្រសួងមានសមត្ថកិច្ចបានចោទថា ជាសេចក្តីថ្លែងការណ៍ប្រកបដោយការញុះញង់រហូតដល់មានឃាតកម្មលើលោករដ្ឋមន្ត្រី កែវ សង់គឹម និងលោកថាច់ជា សមាជិកគណៈកម្មាធិការកណ្ដាល នៃសមាគមបុគ្គលិកសិក្សានោះ ការពិតគឺមិនមែនដូច្នោះឡើយ ។ អ្នកណាជាឃាតករលើលោកកែវ សង់គឹម និងលោក ថាច់ ជា ក្រសួងមានសមត្ថកិច្ចនិងមតិមហាជនក៏បានជ្រាបអស់ហើយ មិនគួរឡើយប៉ុនប៉ងទំលាក់មកលើបុគ្គលិកសិក្សាសោះទេ ។

ចំណែកឯសេចក្តីថ្លែងការណ៍វិញ យើងបានចេញសេចក្តីថ្លែងការណ៍ចំនួន ៣ ជាសាធារណៈជាផ្លូវការ គឺ :

១- សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី ១៧ ឧសភា ១៩៧៤ ដកសេចក្តីទុកចិត្តពីរដ្ឋាភិបាល ឡុង បូរ៉េត ទី ១ ស្របតាមសេចក្តី

សំរេចនៃមហាសន្និបាតវិសាមញ្ញនៃថ្ងៃទី ៥ មេសា ១៩៧៤ ដោយរដ្ឋាភិបាលនេះ គ្មានសមត្ថភាពដោះស្រាយបញ្ហាសង្គមរបស់បុគ្គលិកសិក្សា,

២- សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី ១០ កញ្ញា ១៩៧៤ អំពីអំពើគំរាមកំហែងនៃរដ្ឋាភិបាលលោក ធីវ និងរដ្ឋាភិបាលលោក ធម្មសក្តិ មកលើកោះអាចម៍សេះ ហៅពូលូវៃ,

៣- សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី ២៣ កញ្ញា ១៩៧៤ អំពីវិធានការសេដ្ឋកិច្ចថ្មី របស់រដ្ឋាភិបាល ឡុង បូរ៉េត ទី ២ វិធានការដែលធ្វើឲ្យមានការច្របូកច្របល់គ្រប់មជ្ឈដ្ឋាន នៃសង្គមជាតិ ។

ម្យ៉ាងទៀត ការចោទរបស់លោក ណុប ធុំ បច្ចុប្បន្នប្រធាននៃ គណៈកម្មាធិការកណ្តាលបណ្តោះអាសន្ន នៃមូលនិធិគ្រុសង្គ្រោះដែលថា គណៈកម្មាធិការកណ្តាលបានយកអង្គការសមាគមទៅធ្វើជា " វេទិកាវិទ្ធង្សនា ដើម្បីពន្លិចសាធារណរដ្ឋ " ក៏ប្រាសចាកការពិតដែរ ។ គណៈកម្មាធិការកណ្តាល ពុំដែលធ្វើការអ្វីលួចលាក់បិទមុខ មិនហ៊ានទទួលខុសត្រូវឡើយ ហើយក៏មិនមែនជាទំលាប់របស់គណៈកម្មាធិការកណ្តាលផងទៀត ។

ពត៌មានដូចបានរៀបរាប់ខាងលើ សូមសមាជិក-សមាជិកា នៃសមាគមបុគ្គលិកសិក្សាខ្មែរនិង មហាជន មេត្តាជ្រាប ។

*ភ្នំពេញ, ថ្ងៃទី ៥ ខែតុលា ១៩៧៤*

គណ:កម្មាធិការកណ្តាល

នៃសមាគមបុគ្គលិកសិក្សាខ្មែរ

# ទគ្គទី ៣

# ប្រតិកម្ម

បន្ទាប់ពីសមាគមបុគ្គលិកសិក្សាខ្មែរ ត្រូវរំលាយទាំងកំរោលនាយប់ថ្ងៃទី២៤ កញ្ញា ១៩៧៤ វេលាម៉ោង ២១ មក គេសង្កេតឃើញមានប្រតិកម្មជាច្រើន ពីមជ្ឈដ្ឋានសាធារណជនទូទៅ ពីអ្នករដ្ឋការនៃក្រសួងនានា ពីអង្គការសមាគមដ៏ទៃទៀត ជាពិសេសពីមជ្ឈដ្ឋានបុគ្គលិកសិក្សា ដែលជាសមាជិក-ជិកានៃសមាគមតែម្តង ។ មជ្ឈដ្ឋានបរទេសក៏មានការភ្ញាក់ផ្អើលមិនតិចដែរ ។ អ្នកទទួលខុសត្រូវនៃវិទ្យុទូរទស្សន៍កាណាដា ដោយបានឃើញកាសែតសៀមចុះផ្សាយការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ក៏ធ្វើដំណើរជាពិសេសមកសុំជួបនឹងអ្នកទទួលខុសត្រូវ នៃគណៈកម្មាធិការកណ្តាល ដើម្បីធ្វើសម្ភាសន៍អំពីបញ្ហានេះ ។ អ្នកធ្វើយធ្វងសារពត៌មាននិងអនុពន្ធកាសែតនៃស្ថានទូតបរទេសជាច្រើន ក៏បានទាក់ទងចង់ដឹងពត៌មានអំពីការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរកាលពីថ្ងៃ ២៥ កញ្ញា១៩៧៤នេះ។ មានអ្នកការទូតម្នាក់បានពោលថា “ បើនៅប្រទេសគេវិញ គេមិនបណ្តោយឱ្យរំលាយបែបនេះបានឡើយ ” ។

ប្រតិកម្មទាំងឡាយខាងលើនេះក្រៅពីប្រតិកម្មបុគ្គលិកសិក្សា គ្រាន់តែថាបាតុភាពសំដែងនូវការធ្វល់មួយរយៈពេល នូវការខកចិត្តដែលគេជឿមិន

នឹកស្មានដល់ និងការផ្តន្ទាដោយស្ងៀមស្ងាត់ នូវអំពើមួយដែលប្រព្រឹត្តខុសច្បាប់ ដែលធ្វើឱ្យសាបរលាបដល់សិទ្ធិសេរីភាព និងលទ្ធិប្រជាធិបតេយ្យដែលមានការធានារ៉ាប់រងពីរដ្ឋធម្មនុញ្ញស្រាប់ប៉ុណ្ណោះ ។

ពីមជ្ឈដ្ឋានជាតិ ខាងក្រៅវង្វង់បុគ្គលិកសិក្សា អង្គការនានាក៏បានប្រកាន់យកអាកប្បកិរិយាម៉ឺងម៉ាត់របស់គេ ចំពោះព្រឹត្តិការណ៍រំលាយសមាគមបុគ្គលិកសិក្សាដែរ ។ សមាគមខ្មែរការពារសិទ្ធិមនុស្ស តាមរយៈគណៈកម្មាធិការនាយកបានធ្វើសេចក្តីសម្រេចចិត្តមួយផ្សាយជាសាធារណៈដូចតទៅ :

# សេចក្តីសំរេចចិត្ត

សមាគមខ្មែរការពារសិទ្ធិមនុស្សបានទទួលដំណឹងតាមសារពត៌មានថាសមាគមបុគ្គលិកសិក្សាខ្មែរ " ស - ប - ស - ខ - " ត្រូវបានរដ្ឋាភិបាលសំរេចរំលាយតាមក្រិត្យមួយចុះថ្ងៃទី ២៥ ខែកញ្ញា ១៩៧៤ ។ ជាមួយគ្នានឹងការរំលាយនេះ រដ្ឋាភិបាលថែមទាំងបានចាប់សមាជិក ២ រូបនៃគណៈកម្មាធិការកណ្តាលនេះទៀតផង ។

ចំពោះសេចក្តីប្រកាសជូនដំណឹងរបស់រដ្ឋាភិបាល កាលពីថ្ងៃទី២៥ កញ្ញា ១៩៧៤ គណៈកម្មាធិការនាយកនៃសមាគមយើង មានសេចក្តីរំជួលចិត្តនិងសោកស្តាយជាពន់ពេក ក្នុងការដែលរដ្ឋាភិបាលបានធ្វើខុសច្បាប់

គ្មានសំអាងលើមូលហេតុច្បាស់លាស់ ហើយបានបំពារបំពានទៅលើសិទ្ធិនៃសមាគមមួយ ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋខ្មែរ និងដោយសេចក្ដីថ្លែងការណ៍ជាសកលនៃសិទ្ធិមនុស្ស ។

អំពើដែលរដ្ឋាភិបាលបានទៅរុករើឆែកឆេរ និងរឹបអូសទ្រព្យសម្បត្តិសមាគម ព្រមទាំងការប្រកាសរំលាយ ស-ប-ស-ខ- និងការចាប់ចងបុគ្គលិកសិក្សា ២ រូប ដែលសុទ្ធតែសមាជិកគណៈកម្មាធិការកណ្ដាល នៃសមាគមដោយគ្មានមូលដ្ឋានច្បាស់លាស់នោះ ជាហេតុមួយបញ្ជាក់ឲ្យឃើញច្បាស់ នូវការរំលោភបំពារបំពានផ្ដាច់ការឥតព្រំដែនរបស់រដ្ឋាភិបាលមកលើសមាគមដ៏ធំ និង ចាស់ទុំនេះ ។

ដូចជាសមាគមដទៃទៀតដែរ សមាគមបុគ្គលិកសិក្សាខ្មែរ "ស-ប-ស-ខ-" ត្រូវបានដឹកនាំដោយគណៈកម្មាធិការមួយ ដែលមានប្រធានជាអ្នកទទួលខុសត្រូវ ហើយកិច្ចការផ្សេងៗដែលទាក់ទងតាមផ្លូវតុលាការ ត្រូវតែធ្វើឡើងតាមរយៈគណៈកម្មាធិការនេះ ដែលសមាជិកគ្រប់រូបបានជ្រើសតាំងឡើងតាមលទ្ធិប្រជាធិបតេយ្យ ។

ចំណែកឯការបង្កើតគណៈកម្មាធិការមួយផ្សេងទៀតដែលរដ្ឋាភិបាលបានតែងតាំងដើម្បីដឹកនាំនិងគ្រប់គ្រងសម្បត្តិ " ស ប ស ខ " នេះ ជាអំពើខុសច្បាប់មួយប្រាសចាកលទ្ធិប្រជាធិបតេយ្យ ហើយដែលផ្ទុយនឹងមាត្រា ១៣ នៃលក្ខន្តិកៈរបស់សមាគម ដែលចែងថា "សមាជិកនៃគណៈកម្មាធិការកណ្ដាលត្រូវឲ្យមហាសន្និបាតបោះឆ្នោតរើសសំរាប់ ១ ឆ្នាំ ក្នុងចំណោម

សមាជិកនៃសមាគម ដែលមានទីលំនៅនៅភ្នំពេញ ។ សមាជិកដែលត្រូវគេរើសតាំងហើយដល់ទៅឆ្នាំក្រោយៗ អាចឈរឈ្មោះឱ្យគេរើសទៀតបាន"។

គណៈកម្មាធិការនាយកនៃសមាគមខ្មែរការពារសិទ្ធិមនុស្ស សូមស្នើដោយទទូចដល់រដ្ឋាភិបាលមេត្តាយកគតិយុត្តិធម៌ជាមូលដ្ឋាន ដើម្បីប្រគល់សិទ្ធិទៅគណៈកម្មាធិការកណ្តាល "សបសខ" វិញ ដោយមេត្តាលុបក្រឹត្យប្រធានាធិបតីចុះថ្ងៃទី ២៥ កញ្ញា ១៩៧៤ ហើយមេត្តាបង្គាប់ឱ្យដោះលែងសមាជិកពីររូបនៃគណៈកម្មាធិការកណ្តាល ដែលអាជ្ញាធរបានចាប់ឃុំឃាំងពុំត្រឹមត្រូវតាមលក្ខណៈច្បាប់នោះ ឱ្យមានសេរីភាពជាស្ថាពរ ក្នុងពេលដ៏ខ្លីបំផុតខាងមុខនេះ ។

*ភ្នំពេញ, ថ្ងៃទី ១២ ខែតុលា ១៩៧៤*

ជ - គណៈកម្មាធិការនាយក

នៃសបាគមខ្មែរការពារសិទ្ធិមនុស្ស

ប្រធាន

**ហ៊ុយ ~ កន្ធុល**

# RESOLUTION

L'Associat'on Khmère pour la Défense des droits de l'Homme a été informée par la presse que par un Kret du Président de la République en date du 25 Septembre 1974, le Gouvernement a pris la décision de dissoudre l'Association des Membres du Corps Enseignant Khmer. Cette dissolution a été suivie de l'arrestation de deux membres de son Comité Central.

Sans discuter le bien fondé des motifs donnés par le Gouvernement pour justifier sa décision sans motifs exposés dans son communiqué du 25 Septembre, le Comité Directeur de notre Association ne peut s'empêcher de relever avec émoi et regret, qu'elle est entachée d'illégalité et a porté atteinte aux droits d'association reconnus par la Constitution de la République et la Déclaration Universelle des Droits de l'Homme.

Les actes des autorités notamment ceux consistant à faire perquisionner puis à confisquer les biens de l'A.M.C.E.K., en dehors de la présence de ses responsables sont HAUTEMENT ARBITRAIRES, de même la prononciation par Kret présidentiel de sa dissolution et l'arrestation de deux de ses membres sans motifs légaux.

L'A.M.C.E.K. étant dirigée par un Comité Central avec un président responsable, toute action judiciaire valable droit en effet passer par ce Comité.

De plus, la nomination par le Gouvernement d'un comité chargé de diriger et d'administrer les biens de l'A.M. C.E.K. est un autre acte illégal, car contraire à l'article

13 de ses statuts qui disposent que les membres du Comité Central doivent être élus en Assemblée Générale.

Le Comité de l'Association Khmère pour la Défense des Droits de l'Homme se permet de prier constamment le Gouvernement de bien vouloir, dans un geste de justice et d'équité, rétablir dans tous leurs droits l'AMCEK et son Comité Directeur en faisant abroger le Kret présidentiel du 25 Septembre et faire remettre en liberté les deux personnes illégalement arrêtées.

*Phnom Penh, le 12 Octobre 1974*

P. LE COMITE DIRECTEUR DE L'ASSOCIATION KHMERE POUR LA DEFENSE DES DROITS DE L'HOMME,

LE PRESIDENT,

Signé : HUY KANTHUL

ចំពោះសេចក្ដីសំរេចចិត្តប្រកបដោយសុភវិនិច្ឆ័យនេះ គណៈកម្មាធិការកណ្ដាល កំបានធ្វើលិខិតអំណរគុណមួយជូនសមាគមខ្មែរដើម្បីការពារសិទ្ធិមនុស្ស ដែលមានន័យដូចតទៅ :

សមាគមបុគ្គលិកសិក្សាខ្មែរ **សាធារណរដ្ឋខ្មែរ**

លេខ ៥,វិថីឧញ៉ា ម៉ែន ភ្នំពេញ, ថ្ងៃទី ១៥ ខែតុលា គស ១៩៧៤

លេខ ០១ ៧៤ គក គណៈកម្មាធិការកណ្ដាល នៃសមាគមបុគ្គលិកសិក្សាខ្មែរ

សូមជំរាបលោកប្រធានគណៈកម្មាធិការនាយកនៃសមាគមខ្មែរដើម្បីការពារសិទ្ធិមនុស្ស

ភ្នំពេញ ។

**កម្មវត្ថុ** : សេចក្ដីថ្លែងអំណរគុណ ។

ខ្ញុំសូមជំរាបលោកប្រធានគណៈកម្មាធិការនាយកថាសមាគមបុគ្គលិកសិក្សាខ្មែរ ទើបបានទទួលពត៌មាន ដោយរីករាយសោមនស្ស នូវសេចក្ដីសំរេចចិត្តចុះថ្ងៃទី ១២ ខែតុលា ១៩៧៤ របស់អង្គការដែលមានលោកប្រធាន ជាអ្នកដឹកនាំដ៏វាងវៃ គាំទ្រដោយសប្បុរសដល់សមាគមបុគ្គលិកសិក្សាខ្មែរ ដែលត្រូវអាជ្ញាធរសំរេចរំលាយតាមក្រឹត្យប្រធានាធិបតី ចុះថ្ងៃ

ទី ២៥ កញ្ញា ១៩៧៤ ដោយតំរូវឲ្យរដ្ឋាភិបាលប្រគល់សិទ្ធិទៅ គណៈកម្មាធិការកណ្ដាល នៃសមាគមបុគ្គលិកសិក្សាខ្មែរវិញ និងដោះលែងឲ្យមានសេរីភាពក្នុងពេលជាបន្ទាន់ នូវសមាជិក ពីររូបនៃគណៈកម្មាធិការនេះ ដែលអាជ្ញាធរចាប់ឃុំឃាំង ។ អាកប្បកិរិយានិងឥរិយាបថរបស់សមាគមខ្មែរ ដើម្បីការពារសិទ្ធិមនុស្ស ចំពោះសមាគមបុគ្គលិកសិក្សាខ្មែរបានត្រូវបុគ្គលិកសិក្សាទាំងអស់ និងមហាជនទទួលអបអរនិងវាយតំលៃដ៏ខ្ពង់ខ្ពស់ ។

អាស្រ័យហេតុនេះ ក្នុងនាមសមាជិក-សមាជិកាទាំងអស់ នៃសមាគមបុគ្គលិកសិក្សាខ្មែរ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះសមាគមខ្មែរដើម្បីការពារសិទ្ធិមនុស្ស ជាពិសេសចំពោះគណៈកម្មាធិការនាយក ដែលមានលោកប្រធានជាអ្នកដឹកនាំដ៏ក្លៀវក្លានិងវាងវៃ ។

សូមលោកប្រធានមេត្តាទទួលនូវមនោសញ្ចេតនា ប្រកបដោយសហការ និងភាតរភាព នៃខ្ញុំ ។

ចំលងជូន

- គ្រប់គណៈកម្មាធិការខេត្ត-ក្រុង នៃ ស-ប-ស-ខ ។
- ឯកសារ ។

ជ-គណៈកម្មាធិការកណ្ដាល

នៃសមាគមបុគ្គលិកសិក្សាខ្មែរ

ប្រធាន

ម៉ៅ លន់

សមាគមបុគ្គលិកសិក្សាខ្មែរ

លេខ ៥, វិថីឧកញ៉ាមែន

លេខ ០២ - ៧៤ គក

ភ្នំពេញ, ថ្ងៃទី ១៥ ខែតុលា ១៩៧៤

លោកអគ្គលេខាធិការ នៃគណបក្សប្រជាធិបតេយ្យ

ទីស្នាក់ការលេខ ៣៨, វិថីលង្កា, ភ្នំពេញ

លោកអគ្គលេខាធិការ,

ខ្ញុំសូមជំរាបលោកអគ្គលេខាធិការថា នៅថ្ងៃទី ២៥ កញ្ញា ១៩៧៤ វេលាម៉ោងប្រាំភ្លឺ ក្រុមអាជ្ញាធរមានសមត្ថកិច្ចបានគាស់ទ្វារ ការិយាល័យនៃទីស្នាក់ការរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ស្ថិតនៅលេខ ៥ វិថីឧកញ៉ាមែន ភ្នំពេញ ហើយចូលរុករើ ឆែកឆេរ ទំលុះសោតុទូ ប្រមូលយកសំណុំលិខិត និង សំភារៈមួយចំនួន ។ ការប្រព្រឹត្តនេះ បានធ្វើឡើងដោយគ្មានវត្តមាននៃអ្នកទទួលខុសត្រូវនៃសមាគមផងទេ ហើយជាការបំពារបំពាន រំលោភលើសិទ្ធិសមាគមដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ និង ដោយសេចក្តីថ្លែងការណ៍ជាសកលនៃសិទ្ធិមនុស្ស ។ សមាជិកពីររូបនៃគណៈកម្មាធិការកណ្តាល នៃសមាគមបុគ្គលិកសិក្សាខ្មែរ ក៏ត្រូវឃាត់ខ្លួននៅថ្ងៃដដែលនេះដែរ ដោយគ្មានមូលដ្ឋានច្បាស់លាស់ ។

បន្ទាប់ពីអំពើដូចជំរាបខាងលើ រដ្ឋាភិបាលតាមក្រឹត្យប្រធានាធិបតីលេខ ៦៣២ បស១ ចុះថ្ងៃទី ២៥ កញ្ញា ១៩៧៤ បានសំរេចរំលាយសមាគមបុគ្គលិកសិក្សាខ្មែរដែលជាអង្គការមួយមានចំណាស់ជាងគេ ព្រមទាំងមានសមាជិក-សមាជិកាជាងពីរម៉ឺននាក់ ។

អាស្រ័យហេតុដូចបានជំរាបពីខាងលើ ខ្ញុំសូមស្នើលោកអគ្គលេខាធិការដោយសុទ្ធចិត្ត ពិនិត្យលទ្ធភាពធ្វើអន្តរាគមន៍គាំទ្រសមាគមបុគ្គលិកសិក្សាខ្មែរ ដោយតំរូវឲ្យរដ្ឋាភិបាលបើកសិទ្ធិជូនសមាគមនេះវិញក្នុងពេលជាបន្ទាន់ ។ តរិយាបថប្រកបដោយសុភនិច្ឆ័យរបស់គណបក្សដ៏ខាស់មួយដ៏ធំ ដែលមានលោកអគ្គលេខាធិការជាអ្នកដឹកនាំដ៏វាងវៃ និងត្រូវសមាជិក—សមាជិកា នៃ សមាគមបុគ្គលិកសិក្សាខ្មែរ និង មហាជនទទួលអបអរ ព្រមទាំងវាយតំលៃដ៏ខ្ពង់ខ្ពស់មិនខាន ។

ដោយមានជំនឿលើការយកចិត្តទុកដាក់ របស់លោកអគ្គលេខាធិការចំពោះបញ្ហានេះ ខ្ញុំសូមលោកមេត្តាទទួលនូវមនោសញ្ចេតនាប្រកបដោយសហការនិងភាតរភាពនៃខ្ញុំ ។

ហត្ថលេខា : **ម៉ៃ លន់**

ប្រធានគណៈកម្មាធិការកណ្ដាល
នៃ សមាគមបុគ្គលិកសិក្សាខ្មែរ

គណបក្សប្រជាធិបតេយ្យ
៣៨ វិថីវត្តលង្កា
ទូរស័ព្ទ លេខ ២.៣៨៩០ភ្នំពេញ
លេខ ១៧

ភ្នំពេញ, នៅថ្ងៃទី ១៨ ខែតុលា ឆ្នាំ១៩៧៤

ប្រធានគណកម្មាធិការជាតិនៃគណបក្ស
ប្រជាធិបតេយ្យ

សូមជំរាបមកលោកប្រធានគណៈកម្មាធិការកណ្ដាល
នៃសមាគមបុគ្គលិកសិក្សាខ្មែរ ភ្នំពេញ ។

លោកប្រធាន

តបតាមលិខិតលោក លេខ០២ ៧៤ គក ចុះថ្ងៃទី ១៥ ខែតុលា ១៩៧៤ ក្នុងនាមខ្ញុំជាប្រធានគណៈកម្មាធិការជាតិនៃគណបក្សប្រជាធិបតេយ្យ ខ្ញុំមានសេចក្ដីស្ដាយណាស់ក្នុងរឿងដែលអាជ្ញាធរ បានបិទសមាគមបុគ្គលិកសិក្សាខ្មែរ និងចាប់បុគ្គលិកនៃសមាគមខ្លះផង ។

ប៉ុន្តែក្នុងកាលៈទេសៈដ៏សែនចង្អៀតចង្អល់នេះ ក្នុងនាមនៃគណបក្ស ខ្ញុំពុំអាចមានលទ្ធភាពនឹងធ្វើអ្វីឡើយហួសពីត្រឹមតែសំដែងនូវការសោកស្ដាយយ៉ាងខ្លាំង ដូចខ្ញុំបានបញ្ជាក់ជំរាបសមាជិកនាពេលធ្វើសន្និសីទពីថ្ងៃទី១៣តុលា មុននេះស្រាប់ៗ

សូមលោកទទួលមនោសញ្ចេតនាដ៏ស្មោះអំពីខ្ញុំ

ប្រធានគណៈកម្មាធិការជាតិនៃគណបក្សប្រជាធិបតេយ្យ

ហត្ថលេខា : ចៅ សៅ

ចំណែកខាងបុគ្គលិកសិក្សាវិញ បន្ទាប់ពីចម្លងសែនជ្រៅមកក៏បានប្រមែប្រមូលគ្នាជជែកពិភាក្សា លើចំណុចទាំងឡាយនៃព្រឹត្តការណ៍នេះ ដោយបានសំដែងការក្តៅក្រហាយយ៉ាងខ្លាំង ៗ ការជជែកពិភាក្សាគ្នានេះ បានលទ្ធផលទៅជាសេចក្តីសម្រេចចិត្តជាញត្តិ តវ៉ាទាមទារឲ្យអគ្គការលើលុបក្រិត្យរំលាយសមាគមចោល ហើយតម្រូវឲ្យរដ្ឋាភិបាល បើកផ្លូវឲ្យសមាគមរបស់គេមានសកម្មភាពដូចប្រក្រតីឡើងវិញជាចាំបាច់ជាបន្ទាន់ ៗ ញត្តិចេះតែមានជាហូរហែ ដើម្បីគាំទ្រគ្រប់សកម្មភាពរបស់គណៈកម្មាធិការកណ្តាល ដែលបានធ្វើជារៀងរាបជរាបមក ៗ ញត្តិទាំងឡាយដែលយើងទទួលនោះ មានន័យស្ទើរតែប្រហាក់ប្រហែលគ្នាដែលយើងសំអក័យទោសអំពីសំណាក់ម្ចាស់ញត្តិទាំងឡាយ ដោយយើងសុំចុះតែញត្តិខ្លះប៉ុណ្ណោះ ដើម្បីជាសក្ខីភាពនៃជំរៅចិត្តរបស់គេគ្រប់រូប ៗ

យើងសូមទៀតរំឭកបន្តិចថា ញត្តិទាំងអស់ដែលយើងបានទទួលមកទល់នឹងពេលឡើងពុម្ពសៀវភៅនេះ បានត្រូវធ្វើជាបញ្ជីផ្ញើទៅជូនលោកប្រធានាធិបតីអស់ទៅហើយ ដូចមានបញ្ជីនៅជាប់មកជាមួយនេះស្រាប់ ៗ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្ដាល
លេខ ០៤-៧៤.គក·

**សាធារណរដ្ឋខ្មែរ**

ភ្នំពេញ, ថ្ងៃទី ២៥ ខែតុលា ១៩៧៤

ប្រធានគណៈកម្មាធិការកណ្ដាលនៃបុគ្គលិកសិក្សាខ្មែរ

សូមជំរាបលោកនាយកខុទ្ទកាល័យនៃប្រធានាធិបតី
ភ្នំពេញ ។

លោកនាយក

ខ្ញុំសូមផ្ញើមកជាមួយនូវលិខិតបញ្ជូនញត្តិតវ៉ារបស់បុគ្គលិកសិក្សាស្នើសុំឯកឧត្ដមប្រធានាធិបតី មេត្តាអនុញ្ញាតឲ្យសមាគមបុគ្គលិកសិក្សាខ្មែរមានសកម្មភាពឡើងវិញ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោកនាយកមេត្តាយកលិខិតនិងញត្តិទាំងនេះ ជូនជាពតិមានដ៏ខ្ពង់ខ្ពស់នៃឯកឧត្ដមសេនាប្រមុខប្រធានាធិបតីឲ្យទានដោយអនុគ្រោះ ។

សូមលោកនាយកទទួលនូវសេចក្ដីរាប់អានដ៏ខ្ពង់ខ្ពស់នៃខ្ញុំ ។

ហត្ថលេខា **ម៉ៃ លន់**

សមាគមបុគ្គលិកសិក្សាខ្មែរ ភ្នំពេញ, ថ្ងៃ ទី ២៥ តុលា ១៩៧៤

គណៈកម្មាធិការកណ្តាល

លេខ ០៥-៧៤-គ-ក

ប្រធានគណៈកម្មាធិការកណ្តាលនៃសមាគម

បុគ្គលិកសិក្សាខ្មែរ

សូមជំរាបឯកឧត្តម សេនាប្រមុខប្រធានាធិបតីនៃ

សាធារណរដ្ឋ បុរីចំការមន

ភ្នំពេញ ។

**កម្មវត្ថុ:** សេចក្តីតវ៉ាសុំបើកសមាគមបុគ្គលិកសិក្សាខ្មែរឡើងវិញ

**យោង:** ៣ត្តិរបស់បុគ្គលិកសិក្សាមហាវិទ្យាល័យគរុកោសល្យ ភ្នំពេញ

— ដ — នាយកដ្ឋានទាក់ទងវប្បធម៌

យុវណោស្ហ និងស៊ីម៉េអូ

— ដ — ទីចាត់ការកិច្ចការគរុកោសល្យ

— ដ — នាយកដ្ឋានឧត្តានកម្មនិងការផ្សាយ

— ដ — វិទ្យាស្ថានជាតិនៃខេមរយានកម្ម

— ដ — វិទ្យាល័យចាក់អង្រែ

— ដ — វិទ្យាល័យកម្ពុជបុត្ត

— ដ — វិទ្យាល័យបឹងកេងកង

— ដ — វិទ្យាល័យសេរីសោភ័ណ " បាត់ដំបង "

— ដ — សាលាបឋមសិក្សា សន្ធរម៉ុក

— ដ — — នាគវ័ន

— ដ — — ឫស្សីកែវ

— ដ — — យ៉ាំងមៀង

— ដ — — ឈើរ នាង នាង

— ដ — — សន្សំកុសល

— ដ — — ព្រះកែវមរកត

— ដ — — បាក់ទូក

— ដ — បឋមនិងមធ្យមសិក្សា ខេត្តកណ្តាល

— ដ — — ខេត្តតាកែវ

ខ្ញុំមានកិត្តិយសបញ្ជូនដល់ឯកឧត្តមប្រធានាធិបតី នូវបញ្ជីទី១ នៃញត្តិករបស់បុគ្គលិកសិក្សានៃនាយកដ្ឋាននិងគ្រឹះស្ថានសិក្សានានា ដូចមានចែងក្នុងយោងខាងលើ ប្រឆាំងនឹងការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ដែលរដ្ឋាភិបាលបានចាត់តាមក្រិត្យលេខ៦៣២-បស១ ចុះថ្ងៃទី២៥ ៩-៧៤ៗ ញត្តិរបស់បុគ្គលិកសិក្សាទាំងអស់ខាងលើ មានន័យប្រហាក់ប្រហែលគ្នា ស្នើសុំឯកឧត្តមប្រធានាធិបតីមេត្តាពិនិត្យដោយអនុគ្រោះ ក្នុងពេលដ៏គួរអនុញ្ញាតឲ្យសមាគមបុគ្គលិកសិក្សាខ្មែរ មានសកម្មភាពប្រក្រតីឡើងវិញ ដើម្បីជាការកក់ក្តៅ និងជាទីពំនឹងរបស់គេជងគ្នាទៅអនាគត ។

ទៀតនុកាសនេះ ខ្ញុំសូមអនុញ្ញាតពីឯកឧត្តម ដើម្បីសូមជំរាបដោយគោរពថា ការដែលរដ្ឋាភិបាលបានរំលាយសមាគមមួយ ដែលមានចំណាស់ជិតសាមសិបឆ្នាំមកហើយនេះ នឹងនាំមកជាមួយផលវិបាកគ្រប់បែបយ៉ាងដល់សមាជិក-ជិកា ដែលពីដើមរៀងមកធ្លាប់តែបានទទួលពីអង្គការសង្គមដ៏ធំនេះ នូវការធានារ៉ាប់រងខាងផ្លូវកាយ ផ្លូវសម្ភារៈនិងផ្លូវចិត្ត ដែលសុទ្ធតែជាកត្តាញាំងឱ្យគេជងទាំងពួងមានសន្តិសុខក្នុងអារម្មណ៍រៀងៗខ្លួន ៗ យ៉ាងណាមិញ សមាគមបុគ្គលិកសិក្សាខ្មែរមិនត្រឹមតែផ្តល់ជំនួយមរណភាពដល់សមាជិក-ជិកា ឬគូស្រករស្របច្បាប់ប៉ុណ្ណោះទេ គឺបានផ្តល់ផងដែរ នូវជំនួយ :

— មរណភាពនៃបុគ្គលិការបស់សមាជិក
— មរណភាពនៃមាតាបិតាឬឪពុកក្មេក ម្តាយក្មេកនៃសមាជិក
— ដល់សមាជិកចូលនិវត្តន៍ជាប្រាក់បុរេប្រទាន សំរាប់ទប់ទល់នឹងកង្វះខាត
— ផ្តល់ឱ្យសមាជិក-ជិកាខ្ចីប្រាក់កាសខ្វះៗក្នុងពេលមានអាសន្ន ៗ

ក្រៅពីជំនួយខាងសង្គម ដូចបានពោលជំរាបមកនេះ សមាគមបុគ្គលិកសិក្សាបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីកសាងជាសមិទ្ធិផ្សេងៗមានបដិសណ្ឋារមណ្ឌលជាដើម នៅតាមទីក្រុងឬទីរួមខេត្ត ដើម្បីជាប្រយោជន៍រួមនៃសមាជិក-ជិកា ៗ បដិសណ្ឋារមណ្ឌលទាំងនោះមានតម្លៃរាប់សិបលានរៀល ហើយសព្វថ្ងៃកំពុងតែត្រូវប្រើប្រាស់សំរាប់

បុគ្គលិកសិក្សា ដែលបានភៀសខ្លួនមកពីតំបន់អសន្តិសុខនានានៃសាធារណរដ្ឋ ។

ឯកឧត្តមប្រធានាធិបតី

ក្នុងគ្រួសារបុគ្គលិកសិក្សាទាំងមូល គេជឯមានសន្តានចិត្តជួយធុរៈគ្នាទៅវិញទៅមក ក្នុងបរិយាកាសភាតរភាព សមភាព និងឯកភាព ។ កត្តាទាំងនេះជាខ្លឹមសារ និងជាមូលដ្ឋាននៃសមាគមបុគ្គលិកសិក្សាខ្មែរ ។ ឯលទ្ធផលទាំងនេះមិនមែនត្រូវសំរេចឡើងបានពីមួយថ្ងៃទៅមួយថ្ងៃឡើយ ។

ឯកឧត្តមប្រធានាធិបតី

ការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរនាពេលនេះបានធ្វើឲ្យសមាជិកជិកាគ្រប់រូប មានការស្រងាកចិត្តគ្រប់គ្នា ។ យ៉ាងណាមិញ ស្នាដៃល្អៗដែលគេជឯគ្នាបានកសាងរាប់សិបឆ្នាំ ក៏នឹងត្រូវលាយទៅជាមួយនឹងការរំលាយសមាគមនេះ ។ អំនួតរបស់អង្គការនេះ ក៏នឹងត្រូវសាបសូន្យ ។ សីលធម៌ដែលគេជឯគ្នាព្យាយាមកសាងក៏នឹងត្រូវរង្គោះរង្គើ ។ រីឯទ្រព្យសម្បត្តិសមាគម ដែលត្រូវបានសំរេចដោយពលិកម្មរបស់សមាជិក - ជិកាគ្រប់រូប ក៏នឹងត្រូវវិនាសនៅតាមឲ្យមខេត្ត-ក្រុង ក្នុងសាធារណរដ្ឋ ។

ដោយប្រមើលមើលឃើញនូវហេតុផលដូចបានពោលពីខាងលើ ក្នុងឋានៈជាប្រធាន គ-ក និងក្នុងឋានៈជាសមាជិកមួយរូបនៃសមាគមបុគ្គលិកសិក្សាខ្មែរ ខ្ញុំសូមគាំទ្រទាំងស្រុងនូវញត្តិតវ៉ារបស់បុគ្គលិកសិក្សាទាំងអស់ដូចមានចែងក្នុងយោងខាងលើ ។

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្ដមប្រធានាធិបតីមេត្ដាពិនិត្យដោយយកចិត្តទុកដាក់ ជាពិសេសអនុញ្ញាតឲ្យសមាគមបុគ្គលិកសិក្សាខ្មែរមានសកម្មភាពឡើងវិញដោយអនុគ្រោះ ដើម្បីជាទឹកកក់ក្ដៅដល់សមាជិក-ជិកាតទៅ ។

ដោយមានជំនឿលើទឹកចិត្តយោគយល់និងករុណាធម៌ ដែលឯកឧត្ដមធ្លាប់តែមានតាំងពីដើមរៀងមក ខ្ញុំសូមឯកឧត្ដមសេនាប្រមុខប្រធានាធិបតីមេត្ដាទទួលនូវគារវភក្ដីដ៏ជ្រាលជ្រៅនៃខ្ញុំ ។

ហត្ថលេខា : ម៉ៃ - លន់

---

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្ដាល
លេខ ០៦-៧៤ គក

សាធារណរដ្ឋខ្មែរ
ភ្នំពេញ, ថ្ងៃ ទី ១៦ វិច្ឆិកា ១៩៧៤

ប្រធានគណៈកម្មាធិការកណ្ដាល នៃសមាគមបុគ្គលិកសិក្សាខ្មែរ

សូមជំរាបលោកសេនាប្រមុខប្រធានាធិបតីនៃសាធារណរដ្ឋ បុរីចំការមន-ភ្នំពេញ ។

កម្មវត្ថុ : សេចក្ដីតវ៉ាសុំបើកសមាគមបុគ្គលិកសិក្សាខ្មែរឡើងវិញ

យោង : – ញត្តិរបស់គណៈកម្មាធិការចំរុះ នៃបុគ្គលិកមធ្យមនិងបឋមសិក្សានៃក្រុងភ្នំពេញ និង ខេត្តខ្ទះ

— ញត្តិរបស់បុគ្គលិកសិក្សានៃការិយាល័យបុគ្គលិក នៃទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ
— ញត្តិរបស់បុគ្គលិកសិក្សា នៃនាយកដ្ឋានអនាម័យសិក្សា
— ញត្តិរបស់បុគ្គលិកសិក្សា នៃសាលាបមសិក្សា ផ្សារតូច
— ញត្តិរបស់បុគ្គលិកសិក្សានៃសាលាបឋសិក្សា អ៊ុង ម៉េងតឹក
— ញត្តិរបស់បុគ្គលិកសិក្សា នៃវិទ្យាល័យ ១៨ មីនា ១៩៧០
— ញត្តិរបស់បុគ្គលិកសិក្សា នៃវិទ្យាល័យទួលស្វាយព្រៃ
— ញត្តិរបស់បុគ្គលិកសាលាបឋមសិក្សាបឹងកេងកង
— ញត្តិរបស់បុគ្គលិកវិទ្យាល័យ ប្រិជង្ស

ខ្ញុំមានកិត្តិយសសូមផ្ញើជូនលោកសេនាប្រមុខប្រធានាធិបតី នូវបញ្ជីទី ២ នៃញត្តិតវ៉ារបស់បុគ្គលិកសិក្សាទាំងឡាយ ដូចមានចុះក្នុងយោងខាងលើ ស្នើសុំលោកប្រធានាធិបតី មេត្តាអនុញ្ញាតឱ្យសមាគមបុគ្គលិកសិក្សាខ្មែរ មានសកម្មភាពប្រក្រតីឡើងវិញ ។ ញត្តិទាំងនោះ មានអត្ថន័យប្រហាក់ប្រហែលគ្នាដូចតទៅ :

— បុគ្គលិកសិក្សាប្រឆាំងនឹងការរំលាយ មិនត្រឹមត្រូវតាមលក្ខណៈច្បាប់ នៃ អង្គការសមាគមរបស់គេ ។
— មិនទទួលស្គាល់គណៈកម្មាធិការកណ្តាលបណ្តោះអាសន្ន ដែលក្រសួងអប់រំជាតិបន្តុបឡើង ដោយខ្វះលក្ខណៈប្រជាធិបតេយ្យ

និងលក្ខណៈតំណាង ដោយគេជងទាំងឡាយមិនបានជ្រើសរើសតាមឆន្ទៈរបស់គេ ។

— គេជងទាំងឡាយមិនទទួលដឹងឮនូវសកម្មភាពគ្រប់បែបយ៉ាងដែលគណៈកម្មាធិការនេះយកឈ្មោះបុគ្គលិកសិក្សាទៅធ្វើជាខែលដើម្បីសំរេចនូវគោលបំណងអ្វីមួយ ។

— បុគ្គលិកសិក្សាម្ចាស់ៗត្តិបានប្តេជ្ញាមិនទទួលខុសត្រូវ ចំពោះផលវិបាកជាយថាហេតុ ដែលអាចលេចចេញពីការមិនអនុញ្ញាតឲ្យសមាគមបុគ្គលិកសិក្សាខ្មែរមានសកម្មភាពឡើងវិញ ។

លោកសេនាប្រមុខប្រធានាធិបតី

ការទាមទាររបស់បុគ្គលិកសិក្សាខាងលើ គឺធ្វើឡើងដោយសុទ្ធចិត្ត មានបំណងតែម្យ៉ាងគឺ ឲ្យអគ្គការសមាគមបុគ្គលិកសិក្សា មានសម្មភាពឡើងវិញ ដើម្បីបំរើផលប្រយោជន៍រួមរបស់គេជងគ្នាតែប៉ុណ្ណោះ ។

ក្នុងឋានៈជាប្រធាននៃគណៈកម្មាធិការកណ្តាល នៃ អគ្គការសង្គមដ៏ធំនេះ ខ្ញុំយល់ឃើញថា ការទាមទាររបស់បុគ្គលិកសិក្សាមានលក្ខណៈត្រឹមត្រូវ សមរម្យ ហើយឆ្លើយតបនឹងកាលៈទេសៈបច្ចុប្បន្ននេះផង ។ យ៉ាងណាមិញ មិនត្រឹមតែបានជួយរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាសង្គមមួយផ្នែកធំប៉ុណ្ណោះទេ សមាគមបុគ្គលិកសិក្សាមានមធ្យោបាយគ្រប់គ្រាន់អាចឲ្យគេរស់ដោយខ្លួនឯងបាន ព្រមទាំងធ្វើឲ្យសមាជិក-ជិកាមានការកក់ក្តៅ និង ការសង្ឃឹមជាច្រើនថែមទៀត ។ ម្យ៉ាងទៀត ការបណ្តោត

បណ្ដាយឲ្យមានអំពើពុករលួយគ្រប់របភាព ក្នុងការប្រលងសម័យលើកទីមួយ និងទីពីរ ការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ និង ការបង្កើតគណៈកម្មាធិការកណ្ដាលបណ្ដោះអាសន្ន ជំនួសគណៈកម្មាធិការកណ្ដាលបុគ្គលិកសិក្សាខ្មែរ អំពើទាំងនេះ មតិមហាជន ជាពិសេសមតិបុគ្គលិកសិក្សាស្ទើរតែទាំងអស់ មិនអាចចាត់ទុកជាការចៃដន្យឡើយ ។ គេអាចយល់ថា អំពើទាំងនេះជាគំរោងមួយដែលកំពុងត្រូវអនុវត្តយ៉ាងសកម្ម ដើម្បីបំបែកបំបាក់មហាគ្រួសារដ៏ធំនេះ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោកសេនាប្រមុខប្រធានាធិបតី មេត្តាពិនិត្យបញ្ហានេះដោយសេចក្ដីអនុគ្រោះ តាមសំណើសុំរបស់បុគ្គលិកសិក្សាខ្មែរ ក្នុងពេលដ៏គួរឲ្យទាន ៗ

សូមលោកសេនាប្រមុខប្រធានាធិបតី មេត្តាទទួលនូវគាររវភក្ដីដ៏ជ្រាលជ្រៅនៃខ្ញុំ ៗ

ហត្ថលេខា: ម៉ៃ លន់

# ញត្តិរបស់បុគ្គលិកសិក្សាសាលាដាក់ជូន ជូនចំពោះលោកប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ

— តាមរយៈ លោកប្រធានគណៈកម្មាធិការកណ្ដាល នៃសមាគមបុគ្គលិកសិក្សាខ្មែរ

លោកប្រធានាធិបតី,

— ដោយយល់ឃើញថា ការទាមទារសិទ្ធិសុំរស់ដ៏ត្រឹមត្រូវរបស់បុគ្គលិកសិក្សាមិនទាន់បានទទួលការដោះស្រាយ ពីសំណាក់រដ្ឋាភិបាលនៅឡើយ,

— ដោយយល់ឃើញថា រដ្ឋាភិបាល ឡុង បូរេត ទី២ មិនដោះស្រាយបញ្ហាប្រជាជន តែបែរជាតំលើងថ្លៃទំនិញសព្វសារពើ ដើម្បីសំលាប់ប្រជាជនខ្មែរទៅវិញ,

— ដោយឃើញយល់ថា តំលៃទំនិញសព្វថ្ងៃខ្ពស់ហួសពីប្រាក់បៀវត្សរបស់យើងខ្ញុំឆ្ងាយណាស់ ដែលមិនអាចឲ្យយើងខ្ញុំរស់តទៅទៀតបានទេ,

— ដោយយល់ឃើញថា ការដែលអាជ្ញាធរមានសមត្ថកិច្ចប្រដាប់អាវុធ បាននាំគ្នាទៅលួចគាស់ទ្វារការិយាល័យសមាគមបុគ្គលិកសិក្សាខ្មែរកាលពីថ្ងៃទី២៥ កញ្ញា ១៩៧៤ ទាំងព្រលឹមអុរ ប្លន់យកទ្រព្យសម្បត្តិសមាគមជាអំពើមួយបំពារបំពានលើរដ្ឋធម្មនុញ្ញ និងសិទ្ធិសេរីភាពខាងលំនៅស្ថានរបស់ប្រជាពលរដ្ឋទាំងស្រុង,

— ដោយយល់ឃើញថា ការចោទប្រកាន់លើសមាគមបុគ្គលិកសិក្សាខ្មែរថាជាអ្នកធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបសាធារណរដ្ឋនោះ មិនមែនជាដំ-ណោះស្រាយទេ គឺជាល្បិចចង់សំលាប់ឆ្កែចោទថាឆ្កែនោះឆ្កួតតែប៉ុណ្ណោះ,

— ដោយយល់ឃើញថា អំពើទាំងប៉ុន្មានរបស់រដ្ឋាភិបាលលោក ឡុង បូរេតទី ២នេះ គឺជាការមើលងាយដោយចំហរមកលើអធិបតេយ្យ និងសិទ្ធិរបស់បុគ្គលិកសិក្សាខ្មែរទាំងមូល,

យើងខ្ញុំជាបុគ្គលិកសិក្សាសាលាបាក់ទូក បានសំរេចចិត្តជាឯកច្ឆ័ន្ទដូចតទៅនេះ :

*១- ប្រកាសដកសេចក្ដីទុកចិត្តទាំងស្រុង ពីរដ្ឋាភិបាលលោក ឡុង បូរេតទី២,*

*២- តំរូវឲ្យអ្នកកាន់អំណាចដោះស្រាយជាបន្ទាន់ នូវបញ្ហាទាមទារសិទ្ធិសុំរស់របស់បុគ្គលិកសិក្សាខ្មែរ ឲ្យបានលទ្ធផលជាវិជ្ជមាន,*

*៣- នៅតែទទួលស្គាល់គណៈកម្មាធិការកណ្ដាល នៃសមាគមបុគ្គលិកសិក្សាខ្មែរ និងគណៈកម្មាធិការចំរុះតំណាងបុគ្គលិកសិក្សាខ្មែរជានិច្ចនិងគ្រប់កាលៈទេសៈ,*

*៤- ផ្ដាលទោសយ៉ាងម៉ឺងម៉ាត់បំផុត ចំពោះបុគ្គលនិយមអំណាចផ្ដាច់ការ ដែលរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ហើយទៅបង្កើតគណៈកម្មាធិការមួយផ្សេងទៀត*

ខុសច្បាប់និងប្រាសចាកលទ្ធិប្រជាធិបតេយ្យក្នុងគោលបំណងបំបែកបំបាក់ គោលជំហរដ៏រឹងប៉ឹងរបស់បុគ្គលិកសិក្សាយើង.

៥- នឹងបញ្ឈប់ការងារជាស្ថាពរ នៅបវេសនកាលឆ្នាំសិក្សា ១៩៧៤-៧៥នេះ បើបញ្ហាទាំងអស់ខាងលើពុំបានដោះស្រាយជាវិជ្ជមានពីសំណាក់អ្នកកាន់អំណាច ។

យើងខ្ញុំសូមឲ្យលោកប្រធានាធិបតីទទួលខុសត្រូវទាំងស្រុង ចំពោះផលវិបាកទាំងឡាយ ដែលនឹងកើតមានឡើងដោយថាហេតុ បន្ទាប់ពីអ្នកកាន់អំណាចមិនព្រមដោះស្រាយបញ្ហាខាងលើឲ្យបានទាន់ពេលវេលា ហើយយើងខ្ញុំទាំងអស់គ្នាត្រៀមខ្លួនជាស្រេចនឹងធ្វើពលិកម្ម ដំណាក់ឈាមចុងក្រោយ ដើម្បីការពារ ទាមទារសិទ្ធិសុំរស់ដ៏ត្រឹមត្រូវស្របច្បាប់ និងរក្សាសុខសប្បាយ ឲ្យមានជីវិតគង់វង់តទៅមុខទៀត ។

យើងខ្ញុំមិនព្រមឲ្យជនមួយក្តាប់ដែលពុករលួយ ល្មោភអំណាចហ្វាស៊ីស មកលាក់ខ្លួនក្នុងសង្គម ដើម្បីរំលាយរបបសាធារណរដ្ឋដ៏ប្រពៃនេះបានឡើយ ។

ចំលងជូន :

- លោកប្រធានព្រឹទ្ធសភា
- លោកប្រធានរដ្ឋសភា
- លោករដ្ឋមន្ត្រីទីមួយ
- លោករដ្ឋមន្ត្រីក្រសួងអប់រំ "ដើម្បីជួយដោះស្រាយ"
- អង្គការការពារសិទ្ធិមនុស្ស
- គ្រប់សមាគម "ដើម្បីជាពតិមាន"

សូមលោកប្រធានាធិបតីមេត្តាទទួលនូវគារវភក្តិដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ធ្វើនៅបាក់ទូក ថ្ងៃទី ១៦ ខែតុលា ១៩៧៤

យើងខ្ញុំទាំងអស់គ្នាជាបុគ្គលិកសិក្សា ធ្វើការនៅសាលា បាក់ទូក សូមចុះហត្ថលេខាភ្ជាប់មកជាមួយនេះស្រាប់(១)

---

# ញត្តិរបស់បុគ្គលិកសិក្សានៅវិទ្យាល័យ កម្ពុជបុត្រ

ដោយយល់ឃើញថា ការទាមទាសិទ្ធិរស់របស់បុគ្គលិកសិក្សាដែលមានលក្ខណៈត្រឹមត្រូវមិនទាន់បានទទួលដំណោះស្រាយ ពីសំណាក់អ្នកកាន់អំណាចសព្វថ្ងៃនៅឡើយ ។

ដោយយល់ឃើញថា ការសុំសិទ្ធិរស់នេះជាបំណងប្រាថ្នារបស់ព្រះសង្ឃ កម្មករ យុទ្ធជន យុវជន ប្រជារាស្ត្រ មន្ត្រីរដ្ឋការភាគច្រើនដាច់ខាត ដែលកំពុងតែទទួលនូវទុក្ខវេទនា ស្រែកហោមរោម ខ្វះមុខខ្វះក្រោយពីមួយថ្ងៃទៅមួយថ្ងៃ ។

---

(១) ចញ្ជីហត្ថលេខាមានតែ១សន្លឹក ដែលបានផ្ញើទៅជូនលោកប្រធានាធិបតីហើយ ។

ដោយយល់ឃើញថា ការដែលពួកអាវុធហត្ថជាតិនិងពួកអាជ្ញាធរមានសមត្ថកិច្ចប្រដាប់ដោយអាវុធ បាននាំគ្នាទៅគាស់សោទ្វារការិយាល័យ ស.ប.ស.ខ. កាលពីថ្ងៃទី២៥ កញ្ញា ១៩៧៤ទាំងព្រលឹមអុលយកទ្រព្យសម្បត្តិរបស់សមាគម គឺជាអំពើរំលោភបំពានផ្តាច់ការឥតព្រំដែនរបស់រដ្ឋាភិបាល ។

ដោយឃើញថា «គណៈកម្មាធិការកណ្តាល ស.ប.ស.ខ.» ជាគណៈកម្មាធិការមួយដែលបានជ្រើសរើសឡើងដោយមហាសន្និបាត ដែលបានសំដែងឡើងដោយឆន្ទៈសុទ្ធសាធរបស់សមាជិក-ជិកាទាំងអស់ ហើយប្រកបដោយលទ្ធិប្រជាធិបតេយ្យទៀតផង ។

ដោយយល់ឃើញថា អ្វីៗទាំងអស់ដែលគណៈកម្មាធិការកណ្តាលបានធ្វើ សុទ្ធតែបានបំរើប្រយោជន៍បុគ្គលិកសិក្សាក្នុងក្របខណ្ឌសង្គមកិច្ច ។

ដោយយល់ឃើញថា អាជ្ញាធរបានលួចចាប់ចងលោកអ៊ុង-អ៊ិត និងលោកជា-ប៉ា ជាសមាជិកគណៈកម្មាធិការកណ្តាលនៃសបសខ. យកទៅឃុំឃាំងដោយគ្មានទោសពៃរ៍អ្វីសោះ ។

- យើងបុគ្គលិកសិក្សាធ្វើការនៅវិទ្យាល័យកម្ពុជបុត្រ ដែលមានរាយឈ្មោះនិងចុះហត្ថលេខាភ្ជាប់មកជាមួយនេះ បានសំរេចដូចតទៅ :-

*១ - តំរូវឲយអ្នកកាន់អំណាចដោះស្រាយជាបន្ទាន់ នូវបញ្ហាជីវភាពព្រះសង្ឃ-កម្មករ-យុទ្ធជន-យុវជន-ប្រជារាស្ត្រ-មន្ត្រីរដ្ឋការ ឲ្យបានលទ្ធផលជាវិជ្ជមាន ។*

២ - នៅតែទទួលស្គាល់ជាដាច់ខាតនូវគណៈកម្មាធិការកណ្ដាលនៃសមាគមរបស់យើង.សបសខ.ជានិច្ច និងគ្រប់កាលៈទេសៈទាំងអស់ ។

៣ - មិនទទួលស្គាល់ជាដាច់ខាត នូវជនដែលបានមកតាំងខ្លួនជាគណៈកម្មាធិការកណ្ដាល ឬន់កិច្ចការក្នុងផ្ទៃក្នុង ស.ប.ស.ខ. ដែលគ្មានបានទទួលការបោះឆ្នោតប្រគល់សេចក្ដីទុកចិត្តពីសមាជិក-ជិកា នៃសមាគម ប្រាសចាកពីលទ្ធិប្រជាធិបតេយ្យពិតៗ ។

៤ - សុំឱ្យអ្នកកាន់អំណាចសព្វថ្ងៃ ដោះលែងដោយឥតលក្ខខណ្ឌនូវរូបលោកអ៊ុង-អ៊ុត និង ជា-ជាំ ដែលជាមាសជិកស្មោះត្រង់នៃស-បស-ខ. ព្រមទាំងបុគ្គលិកសិក្សាទាំងអស់ ដែលអាជ្ញាធរចាប់យកទៅឃុំឃាំង ។

៥ - តំរូវឱ្យអ្នកកាន់អំណាចសព្វថ្ងៃដែលបានឃុបឃិតផ្សំគំនិតរំលាយសមាគម សងគ្រឿងសម្ភារៈការិយាល័យ ដែលរឹបអូសដោយគ្មានដីកាតុលាការនោះ មកឱយសមាគមវិញជាបន្ទាន់ ។

៦ - ទាមទារដោយទទូចបំផុត សូមឱ្យលោកប្រធានាធិបតីលុបក្រិត្យចុះថ្ងៃទី២៥-៩-១៩៧៤ ស្ដីពីការប្រកាសរំលាយជាស្ថាពរ នូវស.ប.ស.ខ. ដើម្បីឱ្យសមាគមបុគ្គលិកសិក្សាខ្មែរបានបំរើបុគ្គលិកសិក្សាតទៅទៀតតាមលក្ខន្តិកៈរបស់សមាគម ។

បើលក្ខខណ្ឌទាំងអស់ខាងលើមិនបានទទួល ដំណោះស្រាយទេនោះ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះផលវិបាកគ្រប់យ៉ាង ដែលនឹងកើតមានឡើងដោយថាហេតុក្នុងរឿងនេះទៅថ្ងៃមុខឡើយ ។

បុគ្គលិកសិក្សាទាំងអស់ធ្វើការនៅវិទ្យាល័យកម្ពុជបុត្រ សូមលោកប្រធាន.ស.ប ស.១ ធ្វើអន្តរាគមន៍ទៅអ្នកកាន់អំណាចជាន់ខ្ពស់ នៃសាធារណរដ្ឋខ្មែរ និងអង្គការជាតិ អង្គការអន្តជាតិ ក្នុងសាកលលោក ដែលមានអង្គការមនុស្សធម៌ អង្គការការពារសិទ្ធិមនុស្សជាដើម ឲ្យជួយគាំទ្រដាននិងគាំទ្រតាមគ្រប់រូបភាព នូវសកម្មភាពតស៊ូប្រយុទ្ធដើម្បីសុំសិទ្ធិរស់របស់បុគ្គលិកសិក្សាខ្មែរ ដូចដែលបានរៀបរាប់រចមកហើយនេះ ។

សូមភ្ជាប់មកជាមួយ នូវបញ្ជីរាយឈ្មោះ ព្រមទាំងហត្ថលេខា នៃបុគ្គលិកសិក្សា នៅវិទ្យាល័យកម្ពុជបុត្រ (១)

ធ្វើនៅភ្នំពេញ, ថ្ងៃទី៥ ខែតុលា ១៩៧៤

- ចំលងជូន :

- ខុទ្ទកាល័យប្រតិបត្តិប្រធានាធិបតី
- សភាទាំងពីរ
- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ

- គណបក្សនយោបាយទាំងអស់ក្នុងសាធារណរដ្ឋខ្មែរ
- អង្គការសារពត៌មានជាតិនិងអន្តរជាតិ
- សមាគមវិជ្ជាជីវៈទាំងអស់ក្នុងសាធារណរដ្ឋខ្មែរ
- សមាគមសិស្ស - សមាគមនិស្សិតសាធារណរដ្ឋខ្មែរ
- គណៈកម្មាធិការខេត្ត - ក្រុងទាំងអស់នៃ សបសខ
- បុគ្គលិកសិក្សាទាំងអស់
- សមាគមខ្មែរដើម្បីការពារសិទ្ធិមនុស្ស

(១) ដោយបញ្ជីហត្ថលេខាបានតែ ១ សន្លឹកហើយ ដែលបានផ្ញើទៅជូនលោកប្រធានាធិបតីហើយនោះ យើងពុំអាចរាយឈ្មោះបានឡើយ ។

# ញត្តិ

— ដោយបានស្តាប់ឮតាមវិទ្យុជាតិ ប្រកាសកាលពីថ្ងៃទី ២៥ កញ្ញា ១៩៧៤ វេលាម៉ោង ២២ ថា អាជ្ញាធរមានសមត្ថកិច្ចបានរឹបអូសយកសំភារៈការិយាល័យរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ហើយថែមទាំងបានរំលាយសមាគមទៀត ។

— ដោយបានទទួលពត៌មានពីគណៈកម្មាធិការកណ្តាលកាលពីថ្ងៃទី ២៦ កញ្ញា ១៩៧៤ថា អាជ្ញាធរមាសមត្ថកិច្ចបានតែគេរឹបអូសដោយរំលោភ យកសំភារៈការិយាល័យនៃ - ស - ប - ស - ខ - និងបានប្រកាសរំលាយសមាគមនេះថែមទៀតមែន ។

— ដោយយល់ឃើញថា សមាគមបុគ្គលិកសិក្សាខ្មែរជាអង្គការសង្គមកិច្ចមួយដ៏ធំ ជាសមាគមតែមួយនៅក្នុងសាធារណរដ្ឋខ្មែរ ដែលមានចំណាស់ជាងគេ ហើយដែលមានលក្ខន្តិកៈដំកល់ទុកនៅសាលាវិនិច្ឆ័យតាមច្បាប់ ។

— ដោយយល់ឃើញថា អង្គការសមាគមនេះហើយដែលបានទ្រទ្រង់ជីវភាពគ្រូគ្រប់ជាន់ថ្នាក់ តាំងពីក្នុងសម័យសក្តិភូមិរាជនិយមរហូតមកដល់សម័យសាធារណរដ្ឋនិយមនេះ ។

— ដោយយល់ឃើញថា សកម្មភាពទាំងឡាយរបស់គណៈកម្មាធិការកណ្តាលនៃ សបស ខ ជាសកម្មភាពបំរើផលប្រយោជន៍គ្រូតំណាងមតិរួមរបស់សមាជិក - ជិកាពិតប្រាកដ ។

— ដោយយល់ឃើញថា ការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរមានលក្ខណៈប្រាសចាក និង រំលោភលើលទ្ធិប្រជាធិតេយ្យ ហើយប៉ះពាល់ដល់ជីវភាព និង ផលប្រយោជន៍របស់បុគ្គលិកសិក្សាទាំងប្រទេស ។

— ដោយយល់ឃើញថា គណៈកម្មាធិការថ្មីឧបត្ថកឡើងដោយក្រសួងអប់រំ ពុំមែនកើតឡើងតាមឆន្ទៈនៃសមាជិកទាំងអស់នោះ ។

— ដោយយល់ឃើញថា ចំណោទរបស់រដ្ឋាភិបាលដើម្បីជាលេសរំលាយសមាគម មានលក្ខណៈមិនត្រឹមតែមិនសមហេតុសមផលទេថែមទាំងជាវិធីបំបែកបំបាក់សង្គមគ្រូថែមទៀត ។

អាស្រ័យហេតុនេះ យើងខ្ញុំជាបុគ្គលិកសិក្សា ដែលជាសមាជិក សបស ខ ធ្វើការនៅ វិទ្យាស្ថានជាតិឯកសារសមោធាន ការស្រាវជ្រាវ ការសិក្សានិង ការហ្វឹកហ្វឺនគរុកោសល្យនិង នាយកដ្ឋានឧត្តានកម្មនិង ការផ្សាយ ដូចមានឈ្មោះនិង ចុះហត្ថលេខាខាងក្រោមនេះ សូមប្រណិប័តន៍ចូលមកលោកប្រធានាធិបតី សូមលោកមេត្តាសើរើពិនិត្យសេចក្ដីសំរេចរបស់ក្រិត្យ ដែលរំលាយសមាគមបុគ្គលិកសិក្សាខ្មែរនេះឡើងវិញ ដោយយើងខ្ញុំសុំឲ្យ :

*— បេញក្រិត្យពំកល់ទុកសមាគមយើងខ្ញុំ ឲ្យមានជីវិតនិងសកម្មភាពឡើងវិញ ។*

*— រដ្ឋាភិបាលអនុញ្ញាតច្បាប់ជាពិសេស ឲ្យធ្វើមហាសន្និបាតគ្រូទាំងអស់ ដើម្បីបញ្ចេញមតិលើសកម្មភាពរបស់គណៈកម្មាធិការកណ្ដាល នៃសបសខ ។*

*— រដ្ឋាភិបាលប្ដឹងទៅតុលាការតាមច្បាប់ បើយល់ថាសកម្មភាពនៃគណៈកម្មាធិការកណ្ដាលនៃ ស.ប.ស.ខ. ផ្ទុយនឹងលក្ខន្តិកៈ ។*

*— អាជ្ញាធរមានសមត្ថកិច្ច ដោះលែងសមាជិកគណៈកម្មាធិការកណ្ដាលជាបន្ទាន់ ។*

*យើងខ្ញុំទាំងឡាយសូមបញ្ជាក់ថា យើងខ្ញុំពុំទទួលស្គាល់គណៈកម្មាធិការថ្មីដែលគាត់តែងឡើង ដោយក្រសួងអប់រំ*

ជាផាត់ណាងឆន្ទ នៃយើងខ្ញុំ ឲ្យគ្រប់គ្រងកាន់កាប់ទ្រព្យសម្ប
នៃយើងខ្ញុំជាដាច់ខាត ហើយពុំយល់ព្រមឲ្យជនណាម្នាក់ ឬក្រុ
ជនណាមួយកែប្រែឈ្មោះនិង លក្ខន្តិកៈស.ប.ស.ន. ឡើយ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែកញ្ញា ១៩៧៤

ឈ្មោះ និងហត្ថលេខា

ចំលងជូន :

- ខុទ្ទកាល័យប្រធានាធិបតី
- សភាទាំងពីរ
- ក្រសួងអប់រំ
- គណៈកម្មាធិការកណ្តាល
- គណៈកម្មាធិការក្រុងភ្នំពេញ ។

១- យី - ខៀវ
២- ស៊ុំ - ម៉ន
៣- ម៉ៅ - សាម៉ុន
៤- ពិន - សម្ភាឈាត

៥- ទូច ឈាងឡេង
៦- ឡេង យក់ស្រី
៧- ទីន សាម៉ុល
៨- ឡៅ សាន
៩- កែ សំផុន
១០- សេង ប៊ិន

១១-មិន យិនយក់
១២-មិន ទិប
១៣-នូ ថុក
១៤-អ៊ុយ សែន
១៥-ពេជ អុន
១៦-ចៅ សុំ
១៧-ឈឹម ស៊ុណា
១៨-ខារ ស៊ុយ
១៩-សាយ ហៀង
២០-នៅ ឃៀន
២១-អ៊ុក វង្ស
២២-ង៉ែត ហម
២៣-ស៊ុម អេវឆេង
២៤-អ៊ុក សារុន
២៥-ផា សាកន
២៦-យ៉ែម មាន
២៧-ហូ គុន
២៨-ហ៊ុយ គុង
២៩-ជួន សំបាត់
៣០-នុន ស៊ុក
៣១-អ.ស ម៉ែលន់
៣២-នេត សារៀង
៣៣-ជ័យ សារៀន
៣៤-ព្រាប ចន់
៣៥-ដៀ ភៀន
៣៦-ប៉ោរ ស៊ីម៉ុង
៣៧-ប៉ែន ងៀន
៣៨-អ៊ុង ស្រ៊ុន
៣៩-អ៊ុន ធិប
៤០-គិម ថាន់
៤១-អ៊ី ប៊ុនយ៉ុ
៤២-តាន់ សុមេន
៤៣-ដាំ ឡេង
៤៤-អ៊ុំ អៀន
៤៥-មុម សំអៀន
៤៦-អ្នកស្រី នូវ ជុនគុច
៤៧-អ្នកស្រី អ៊ុក ស៊ុសូត្រ
៤៨-ក. ម៉ែន ស៊ុថា

| | |
|---|---|
| ៤៩ - ឡាច ផនហោ | ៥៥ - អ.ស គួច វ៉ាន |
| ៥០ - អ.ស ឈៀង សាអាត | ៥៦ - អ.ស គង់ ហួត |
| ៥១ - អ.ស យាង យន់ | ៥៧ - អ.ស ឡឹក បូណា |
| ៥២ - អ.ស សំម សាអ៊ុក | ៥៨ - អ.ស ឌិន អឿន |
| ៥៣ - អ.ស អ៊ុង ពិរតន៍ | ៥៩ - អ.ស ម៉ៅ ឌុច |
| ៥៤ - អ.ស ហ៊ុន ថែម | ៦០ - អ.ស ម៉ី វ៉ិន |

---

# ញត្តិបុគ្គលិកសិក្សាវិទ្យាល័យចាក់អង្រែ

ជូនចំពោះលោកប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ

តាមយៈលោកប្រធានគណៈកម្មាធិការ នៃសមាគមបុគ្គលិកសិក្សាខ្មែរ ក្រុងភ្នំពេញ

លោកប្រធានគណៈកម្មាធិការកណ្តាល នៃសមាគមបុគ្គលិកសិក្សាខ្មែរ

— លោកប្រធានាធិបតី

ដោយបានដឹងថា នៅថ្ងៃ ២៥ កញ្ញា ១៩៧៤ មានក្រិត្យលេខ ៦៣២-៧៤ ប.ស.ខ. រំលាយសមាគមបុគ្គលិកសិក្សាខ្មែរ " ស.ប.ស.ខ. " ។

ដោយយល់ឃើញថា ការប្រកាសរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ដែលមានកំណើតតាំងពីឆ្នាំ ១៩៤៧ មកនេះ ជាការមួយធ្វើឡើងដោយខុសច្បាប់ គ្មានសំអាងលើមូលហេតុច្បាស់លាស់ ហើយបានបំពារបំពានលើ

សិទ្ធិនៃគមាគមមួយ ដែលរដ្ឋធម្មនុញ្ញសាធារណរដ្ឋបានទទួលស្គាល់ ។

ដោយយល់ឃើញថា ការរំលាយ ស.ប.ស.ខ ជាការបំពានលើសិទ្ធិពលរដ្ឋ ដែលមានចែងក្នុងសេចក្តីថ្លែការណ៍ជាសាកលនៃសិទ្ធិមនុស្ស ។

ដោយយល់ឃើញថា កាចូលរុករើទីស្នាក់ការ ស.ប.ស.ខ. និង ការចាប់ឃុំឃាំងលោក ជា ប៉ា និងលោកអ៊ឹង អ៊ុត សមាជិកគណៈកម្មាធិការកណ្តាល ដោយគ្មានមូលដ្ឋានច្បាស់លាស់ ជាការរំលោភបំពារបំពានផ្តាច់ការឥតព្រំដែនរបស់រដ្ឋាភិបាលមកលើសមាគមដ៏ធំនិងចាស់ទុំនេះ ។

ដោយយល់ឃើញថា សបសខ មានគណៈកម្មាធិការកណ្តាលនិងគណៈកម្មាធិកាក្រុង-ខេត្ត ដែលធ្វើឡើងដោយវិធីបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យពិតៗ ។

ដោយយល់ឃើញថា តាមលក្ខន្តិកៈសបសខ មានតែមហាសន្និបាតដែលអាចសំរេចរំសាយសនារបស់គណៈកម្មាធិកាកណ្តាល ក្រុង ឬខេត្ត

ដោយយល់ឃើញថា ការតែងតាំងគ្រូមួយក្រុមតូចដោយរដ្ឋាភិបាលឱយដណ្តើមកាន់កាប់មូលនិធិសមាគម ជាការជុយទីងលទ្ធិប្រជាធិបតេយ្យផង ជុយនិងលក្ខន្តិកៈសបសខ ត្រង់មាត្រា ១៣ ផង ។

*យើងខ្ញុំទាំងអស់គ្នា ជាសមាជិក សបសខ សំរេចចិត្តយ៉ាងម៉ឺងម៉ាត់ដូចតទៅ :*

*១- សូមឲ្យលុបព្រឹត្យរំលាយ សបសខ ចុះថ្ងៃទី ២៥-៩-៧៤ ដោយប្រគល់សិទ្ធិទាំងស្រុងទៅ សបសខ វិញ,*

២- សូមឱ្យដោះលែងលោក ផា ប៉ា និងលោកអ៊ឹង អ៊ិត ដែលជាសមាជិកគណៈកម្មាធិការកណ្តាល សបសខ,

៣- សូមឱ្យរដ្ឋាភិបាលដោះស្រាយបញ្ហារស់នៅ របស់បុគ្គលិកសិក្សាជាបន្ទាន់ ,

៤- យើងខ្ញុំពុំទទួលស្គាល់គណៈកម្មការ តែងតាំងដោយរដ្ឋាភិបាលជាដាច់ខាត ,

៥- យើងទទួលស្គាល់ និងគាំទ្រតែសមាគមបុគ្គលិកសិក្សាខ្មែរ " ស.ប.ស.ខ "

៦- បើពុំបានសំរេច យើងខ្ញុំនឹងធ្វើកូដកម្មឱ្យមានកំរិតខ្ពស់ខ្លាំងថែមទៀត ។

អាស្រ័យហេតុនេះ សូមលោកប្រធានាធិបតី មេត្តាពិនិត្យតាមការគួរ

ធ្វើនៅភ្នំពេញ ថ្ងៃ ១១ តុលា ១៩៧៤

យើងខ្ញុំបុគ្គលិកសិក្សាវិទ្យាល័យចាក់អង្រែ

ដែលបានចុះឈ្មោះនិងហត្ថលេខាភ្ជាប់មកជាមួយនេះ

## ហត្ថលេខាអ្នកយល់ស្របនឹងសេចក្តីញត្តិនេះ

| លេខរៀង | នាមនិងគោត្តនាម |
|---|---|
| ១ | ឈឹម ប៉េងលាង |
| ២- | ឆយ សុក |
| ៣- | អ៊ុយ ទីម៉ន |
| ៤- | ពូ សិ |
| ៥- | យក់ ចាន់ធូ |

៦- ប៉ាវ សុក
៧- រស់ សារន
៨- ហ៊ុល អ៊ុន
៩- គឹម ណុល
១០- នង ហួត
១១- យៀង យី
១២- នេត ហឿន
១៣- លឹម ស៊ាមហេង
១៤- ប៉ាន់ ឈៀងហេង
១៥- អ៊ុក មឿន
១៦- បាន ប៊ុនលី
១៧- ឡុង ស៊ុដេត
១៨- ក.ជាម សាង
១៩- អ៊ុម សុត
២០- ជិន យឿន
២១- ង៉ូវ លាងស្រ៊ុន
២២- យីវ គឹមឈន
២៣- លី ស៊ាងគ្រី
២៤- ប៊ុន ឈុនទៀង
២៥- ឡាយ សយ
២៦- ចៅ ប្រេ
២៧- ក. តាំង ស៊ុវឡេង
២៨- គុង ភីនណារី
២៩- ឡៅ គីចជីវ
៣០- ប៊ូ អ៊ុន
៣១- ឯក ឈុនលាង
៣២- ស៊ុន ហុងសាន
៣៣- មាស ឈិត
៣៤- ង៉ូវ ជន
៣៥- អ.ស. អ៊ុង ស៊ុថន
៣៦- ពិត ឈៀងអាន
៣៧- ងិន សារុន

# ញត្តិរបស់បុគ្គលិកសិក្សានៅនាយកដ្ឋាន ការទាក់ទងវប្បធម៌ គណៈកម្មាធិការខេមរជាតិយូណេស្កូ និងគណៈកម្មការខេមរជាតិ ស៊ីម៉េអូ

— ដោយយល់ឃើញថា ការទាមទារសិទ្ធិរស់របស់បុគ្គលិកសិក្សាដែលមានលក្ខណៈត្រឹមត្រូវតាំងពីដើមរៀងមក នៅពុំទាន់បានទទួលការដោះស្រាយពីសំណាក់អ្នកកាន់អំណាចសព្វថ្ងៃនៅឡើយ ។

— ដោយយល់ឃើញថា ការសុំសិទ្ធិរស់នេះជាសេចក្ដីប៉ងប្រាថ្នារបស់ព្រះសង្ឃ កម្មករ យុទ្ធជន យុវជន មន្ត្រីរដ្ឋការភាគច្រើនដាច់ខាត ដែលកំពុងទទួលនូវសេចក្ដីលំបាកវេទនាក្ររហេមរហាម ខ្វះមុខខ្វះក្រោយពីមួយថ្ងៃទៅមួយថ្ងៃ ។

— ដោយយល់ឃើញថា សមាគមបុគ្គលិកសិក្សា "សបស១" ជាសមាគមមួយ ដែលកើតឡើយដោយពលិកម្មគ្រប់បែបយ៉ាង នៃបុគ្គលិកសិក្សាទូទៅ ដើម្បីការពារប្រយោជន៍បុគ្គលិកសិក្សាជាសមាជិក ក៏ដូចជាប្រជាពលរដ្ឋទូទៅដែរ តាំងពីជិត ៣០ឆ្នាំមកហើយ ។

— ដោយយល់ថា "គណៈកម្មាធិការកណ្ដាលសបស១" ជាគណៈកម្មាធិការមួយដែលបានជ្រើសរើសឡើងដោយមហាសន្និបាត ដែលបានសំដែងឡើងដោយឆន្ទៈសុទ្ធសាធរបស់សមាជិកទាំងអស់ ហើយប្រកបដោយលទ្ធិប្រជាធិបតេយ្យ ។

— ដោយយល់ឃើញថា អ្វីៗទាំងអស់ដែលគណៈកម្មាធិការកណ្ដាលបានធ្វើ សុទ្ធតែបានបំរើផលប្រយោជន៍គ្រូ ជាពិសេសក្នុងក្របខណ្ឌសង្គមកិច្ច ។

— ដោយយល់ឃើញថា ការចាប់ចង់បុគ្គលិកសិក្សាជាពិសេសសមាជិកខ្ទះនៃគណៈកម្មាធិការកណ្ដាលកាលពីថ្ងៃទី ២៥-៩-៧៤ នេះ គឺជាការរំលោភមកលើសិទ្ធិគ្រូ ពោលគឺជាការរំលើងលទ្ធិប្រជាធិបតេយ្យ ។

យើងបុគ្គលិកសិក្សាធ្វើការនៅនាយកដ្ឋានការទាក់ទងវប្បធម៌ គណៈកម្មការខេមរជាតិយូណេស្កូ និងគណៈកម្មការខេមរជាតិស៊ីម៉េអូ ដែលមានរាយនាមមិនចុះហត្ថលេខាភ្ជាប់មកជាមួយនេះ បានសំរេចដូចតទៅ៖

*១-នៅតែទទួលស្គាល់ជាដាច់ខាត នូវគណៈកម្មាធិការកណ្ដាល នៃសមាគមរបស់យើង «សបសខ» ដែលយើងបានជ្រើសរើស ហើយទាត់ចោលទាំងស្រុង នូវការរំលាយដោយរំលោភមកលើសមាគមនេះ ព្រមទាំងមិនទទួលស្គាល់យ៉ាងដាច់អហង្ការ នូវគណៈកម្មាធិការចាប់ដាក់ដែលមិនបានទទួលការទុកចិត្តពីសមាជិកទាំងអស់ ។*

*២-សុំឲ្យអ្នកកាន់អំណាចសព្វថ្ងៃ ដោះលែងដោយឥតលក្ខខណ្ឌ នូវលោក អ៊ុង រិត និង ជា ចាំដែលជាសមាជិកស្មោះត្រង់នៃ សបសខ ព្រមទាំងបុគ្គលិកសិក្សាទាំងអស់ ដែលអាជ្ញាធរបានចាប់ដោយស្វាត់ៗ ។*

៣-តំរូវឲ្យអាជ្ញាធរ «សាធារណរដ្ឋខ្មែរ» ដោះស្រាយជាបន្ទាន់ នូវបញ្ហាជីវភាពព្រះសង្ឃ កម្មករ យុទ្ធជន យុវជន មន្ត្រីរដ្ឋការ បុគ្គលិកសិក្សា និងប្រជាពលរដ្ឋភាគច្រើនដាច់ខាត ដែលឥឡូវនេះស្ថានភាពសង្គមកិច្ច សម្ភារៈ សីលធម៌ ត្រូវធ្លាក់ធ្លាក់ចុះយ៉ាងគួរឲ្យសោកស្តាយ ។

៤-សូមលោកប្រធានសមាគមបុគ្គលិកសិក្សាខ្មែរ សបសខ មេត្តាលែលកធ្វើមហាសន្និបាតប្រចាំឆ្នាំឲ្យឆាប់ក្នុងពេលដ៏ខ្លីខាងមុខនេះ ដើម្បីឲ្យសមាជិកទាំងអស់បញ្ចេញយោបល់ ដើម្បីការពារផលប្រយោជន៍របស់សមាគម ស.ប.ស.ខ យើងតទៅ ។

បើលក្ខណ្ឌទាំងអស់ខាងលើ មិនបានទទួលដំណោះស្រាយទេនោះ យើងខ្ញុំនឹងពុំទទួលខុសត្រូវចំពោះផលវិបាកគ្រប់បែបយ៉ាង ដែលនឹងអាចកើតមានឡើងដោយថាហេតុក្នុងរឿងនេះទៅថ្ងៃមុខឡើយ ។

បុគ្គលិកសិក្សាទាំងអស់ ធ្វើការនៅនាយកដ្ឋានការទាក់ទងវប្បធម៌ គណៈកម្មការខេមរជាតិ យូណេស្កូ និងគណៈកម្មការខេមរជាតិស៊ីម៉េអូ សូមលោកប្រធាន ស.ប.ស.ខ ធ្វើអន្តរាគមន៍ទៅអ្នកកាន់អំណាចជាន់លើនៃសាធារណរដ្ឋខ្មែរនិងទៅអង្គការជាតិ អង្គការអន្តរជាតិក្នុងសាកលលោកមាន អង្គការមនុស្សធម៌ អង្គការការពារសិទ្ធិមនុស្ស អង្គការសុខភាពពិភពលោក អង្គការយូណេស្កូ សមាគមវិជ្ជាជីវៈនានាជាដើម ឲ្យជួយ

តាមដានទិងគាំទ្រតាមគ្រប់រូបភាពនូវសកម្មភាពតស៊ូប្រយុទ្ធដើម្បីសុំ «សិទ្ធិរស់»របស់យើង ដូចដែលបានរៀបរាប់រួចមកហើយនេះ ។

សូមជូនភ្ជាប់មកជាមួយនេះនូវបញ្ជីរាយនាម ព្រមទាំងហត្ថលេខា នៃបុគ្គលិក ធ្វើការនៅនាយកដ្ឋានទាក់ទងវប្បធម៌ គណៈកម្មការខេមរជាតិយូណេស្កូនិងគណៈកម្មការខេមរជាតិស៊ីម៉េអូ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៧៤

ចំលងជូន :

— ខុទ្ទកាល័យប្រតិបត្តិប្រធានាធិបតី
— សភាទាំង២
— ទីស្តីការរដ្ឋមន្ត្រីទី១
— ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ
— គណបក្សនយោបាយទាំងអស់ក្នុងសាធារណរដ្ឋខ្មែរ
— អង្គការសារពត៌មានជាតិនិងអន្តរជាតិ
— សមាគមវិជ្ជាជីវៈទាំងអស់ក្នុងសាធារណរដ្ឋខ្មែរ
— សមាគមសិស្ស សមាគមនិស្សិតសាធារណរដ្ឋខ្មែរ
— គណៈកម្មាធិការខេត្ត-ក្រុងទាំងអស់នៃ ស.ប.ស.ខ.
— បុគ្គលិកសិក្សាទាំងអស់ ។

## ឈ្មោះរបស់បុគ្គលិកសិក្សា ធ្វើការនៅនាយកដ្ឋាន ការទាក់ទងវប្បធម៌ក/ក ឃុណេកស្ទ និង គ/កស៊ីម៉េអ៊ូ ចុះថ្ងៃទី ៣០ ៩.៧៤

១- សុក សំអ៊ុល
២- អៀម សុងហេង
៣- កោះ យៀន
៤- ហាវ ព្រែន
៥- នេត ប្រាចទិត
៦- ទីវ ទីណូរ៉ូ
៧ ហង់ ស៊ិនហេង
៨- ទូច ផល
៩- ជឹម ជួន
១០- ប៉ែន សារ៉ែន
១១ អៀង ប៊ុនម៉េង
១២- សួរ អ៊ុន
១៣- សៀ កូ
១៤- កែវ គី
១៥- កាន្ត ជួន
១៦- ហាក់ ត្រី
១៧- គង់ លីឈាង
១៨- ពៅ សារឿង
១៩- ឈន ហៃណាំ
២០- អៀង ប៊ុនម៉េង
២១- ឡឹង សារិទ្ធ
២២- ហ៊ុង សារ៉ាន
២៣- ថាន់ ប៊ុនថេត
២៤- HOK Villaketh
២៥- បាក់គា គឹមតាំង
២៦- មាស សុខ
២៧- កយ ជួន
២៨- ញ៉ុក ថៃសិទ្ធិ

២៩- អ៊ុង ណាំដេង
៣០- លឹម ស៊ិន
៣១- កង ជួន
៣២- លី យាងសេង
៣៣- ជុំ ទ្រី
៣៤- ទូច ឡាក់
៣៥- ក. ហួត នាង យិន
៣៦- ម៉ុម ជីមហ៊ុយ
៣៧- យឹម គឹមហាន
៣៨- សោម សារី
៣៩- អ្នកស្រី ហង្ស សុខុម
៤០- ទឹម សាទ
៤១- ចាប ពុត
៤២- ហ្សី ដេង
៤៣- ឡៅ សុគុន
៤៤- ខៀវ រ៉ែន

---

## សាធារណរដ្ឋខ្មែរ

គណៈកម្មាធិការចំរុះតំណាងបុគ្គលិក
នៅមធ្យម និង បឋមសិក្សា
ក្រុងភ្នំពេញ និង ខេត្តខ្លះ
លេខ : ១៧ - គធិចំបុមប - ភព - ខខ

## ញត្តិគណៈកម្មាធិការចំរុះ

តំណាងបុគ្គលិក នៅមធ្យមសិក្សា និង បឋមសិក្សាក្រុងភ្នំពេញ និង ខេត្តខ្លះ ជូនចំពោះលោកប្រធាន សមាគមបុគ្គលិកសិក្សាខ្មែរ

ការទាមទារសិទ្ធិរស់របស់បុគ្គលិក

— ដោយយល់ឃើញថា សិក្សាខ្មែរ ពុំទាន់ទទួលការដោះស្រាយអំពីរដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរ ដែលឡើងកាន់អំណាចមកនោះទេ ,

— ដោយយល់ឃើញថា ការទាមទារ " សិទ្ធិរស់ " របស់បុគ្គលិកសិក្សាខ្មែរនេះ ពុំគ្រាន់តែមិនបានទទួលការដោះស្រាយប៉ុណ្ណោះទេ គឺថែមទាំងបានទទួលការបន្ទុះបង្អាប់មួលបង្កាច់រករឿងព្យាបាទ កំហែងគំរាមចាប់ដាក់គុកជាដើម យ៉ាងជូរចត់ អំពីពពួកអ្នកកាន់អំណាចនៃសាធារណរដ្ឋខ្មែរ,

— ដោយយល់ឃើញថា សកម្មភាពរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ជាពិសេសសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ២៣ - ៩ - ៧៤ ដែលពុំយល់ស្របចំពោះវិធានការតំឡើងថ្ងៃទំនិញ ពី១ដងទៅ៣ដងថែមទៀត និងដែលបញ្ជាក់ជាថ្មីម្តងទៀត នូវការដកសេចក្តីទុកចិត្តរបស់បុគ្គលិកសិក្សាខ្មែរ អំពីរដ្ឋាភិបាលអត់សមត្ថភាពឃីរហោ " ឡុង បូរេត ទីពីរ " នោះសុទ្ធតែជាតំណាងឆន្ទៈពិតប្រាកដ របស់បុគ្គលិកសិក្សាខ្មែរ ភាគច្រើនដាច់ខាត ,

— ដោយយល់ឃើញថា ស.ប.ស.ខ. ដែលជាអង្គការបេះដូង របស់បុគ្គលិកសិក្សាខ្មែរ កើតឡើងដោយវិធីបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យត្រឹមត្រូវ មិនមែនតាមវិធីទុច្ចរិតលួចសន្លឹកឆ្នោតប្រជារាស្ត្រនោះទេ ហើយដែលមានអាយុតាំងពីសម័យរាជនិយមជិត ៣០ ឆ្នាំរួចមក ហើយនោះ បានត្រូវអ្នកកាន់អំណាចប្រដាប់អាវុធយ៉ាងសន្ធាប់នៃ " សាធារណរដ្ឋខ្មែរ " ឡោមព័ទ្ធ រឹបអូស យកសម្ភារៈមួយចំនួនរបស់សមាគម

ហើយបានប្រកាសរំលាយសមាគមបុ. សិ. ខ្មែរនេះ ដោយរំលោភលើសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋកាលពីថ្ងៃ ២៥ កញ្ញា ១៩៧៤,

— ដោយយល់ឃើញថា នៅថ្ងៃដដែលនេះតំណាងដ៏ស្មោះត្រង់របស់បុគ្គលិកសិក្សាខ្មែរ ២ រូប គឺលោក ជា ប៉ានិង អ៊ុង អ៊ុត បានត្រូវអាជ្ញាធរទាំងនេះចាប់យកទៅឃុំឃាំងដោយអយុត្តិធម៌ដុយអំពីពួក "សៀមបាងកក" និងជាពិសេស "យួនព្រៃនគរ" ដែលបានស្រេកកំហែងយ៉ាងព្រហើនដើម្បីប្លន់យកកោះ "អាចម៍សេះ" របស់ខ្មែរ និង ពួកល្បើងសង្គមដូចជាពួកអ្នកដឹកនាំពុករលួយដល់ឆ្អឹងខ្លះ ពួកល្បញទុច្ចរិត ចិន-យួន ឬបន "មេត្រូនិងកូនត្រូ" មួយក្ដាប់តូច ដែលច្រើនជាដៃជើងនៅក្នុងបណ្ដាញរបស់ពួកគេ ហើយដែលកំពុងតែខំប្រឹងប្រែងប្រទាក់ក្រឡាយកមណ្ឌលប្រលង ធ្វើជាផ្សារលក់សញ្ញាបត្រជាតិយ៉ាងព្រហើនខុសច្បាប់ ។ ម្នាក់ ៗ ប្រមូលប្រាក់បានរាប់លានរៀល ចាយវាយ ៣ យផ្សារព្រឹកល្ងាច ស៊ីផឹក រាំរែក ស្រីស្រាល្បែងពាលា ម៉ូតូថ្មី ឡានថ្មីប្លែក សប្បាយអស្ចារ្យ ដើម្បីបំផ្លាញនូវអ្វីៗ ដែលជាគ្រឹះនៃ "សាធារណរដ្ឋខ្មែរថ្មី" ជាដើមនោះ សុទ្ធតែមានសំណាងយ៉ាងខ្ពស់បំផុត ដោយពុំគ្រាន់តែមិនបានទទួលការរកឿងដាក់ទណ្ឌកម្ម ឬ ទារុណកម្មអំពីរដ្ឋាភិបាលក្រុងភ្នំពេញទេ គឺថែមទាំងបានទទួលការឧបត្ថម្ភគាំទ្រ ឃុបឃិតគ្នា និង គោតសរសើរយ៉ាងគគ្រឹកគគ្រេងពីពួកគេជង ៗ ពួកក្បត់ ឬ ពួកព្រួនសង្គមទាំងនេះហើយឬ ដែលជាអ្នកស្មោះត្រង់និង ជាសសរទ្រទ្រង់សាធារណរដ្ឋខ្មែរសព្វថ្ងៃនេះ ? 7

— ដោយយល់ឃើញថា ញត្តិទាំងឡាយកាន់តែមានចំនួនច្រើនឡើងៗ ចេញអំពីគ្រឹះស្ថានសិក្សានានា ដើម្បីតវ៉ាប្រឆាំងនឹងវិធានការតំលើងថ្លៃទំនិញ និង រំលាយ ស.ប.ស.១,

— ដោយយល់ឃើញថា "ការរស់នៅ" ជាសិទ្ធិរបស់មនុស្សសត្វ ដែលច្បាប់ធម្មជាតិក្តី ច្បាប់អន្តរជាតិក្តី ច្បាប់ស្រុកខ្មែរក្តី បានទទួលស្គាល់ឥតប្រកែកបានឡើយ ,

អាស្រ័យទៅលើហេតុដូចបានរៀបរាប់ខាងលើនេះ គណៈកម្មាធិការចំរុះតំណាងបុគ្គលិកនៅមធ្យមសិក្សា និង បឋមសិក្សាក្រុងភ្នំពេញ និងខេត្តខ្លះ សូមឲ្យលោកប្រធានសមាគមបុគ្គលិកសិក្សាខ្មែរ មេត្តាធ្វើអន្តរាគមន៍ ដើម្បីការពារកិត្តិយស និង ផលប្រយោជន៍របស់បុគ្គលិកសិក្សាខ្មែរទាំងអស់ ហើយសូមប្រកាសជាឧឡារិកថា :

*— តំរូវឲ្យរដ្ឋាភិបាលដោះស្រាយជាបន្ទាន់ នូវបញ្ហាក្រពះរបស់បុគ្គលិកសិក្សាខ្មែរ ក៏ដូចជាប្រជាពលរដ្ឋភាគច្រើនដាច់ខាតដែរ ,*

*— សមាគមបុគ្គលិកសិក្សាខ្មែរ ជាពិសេសសេចក្តីថ្លែងការណ៍ចុះថ្ងៃទី ២៣ – ៩ – ៧៤ ជាតំណាងឆន្ទៈពិតប្រាកដរបស់បុគ្គលិកសិក្សាខ្មែរទូទាំងប្រទេសភាគច្រើនដាច់ខាត ប៉ុន្តែវាគ្រាន់តែពុំបានបំរើផលប្រយោជន៍ដ៏ខ្មៅងងឹត របស់ពួកឈ្មើងជញ្ជក់ឈាមរាស្ត្រប៉ុណ្ណោះទេ ។ ដូច្នោះ តំរូវឲ្យរដ្ឋាភិបាល*

យល់ព្រមឱ្យសមាគម ដែលជាដើមរបស់គ្រូនេះកើតឡើងវិញក្នុងពេលដ៏ឆាប់បំផុត ,

– មិនទទួលស្គាល់ពេទ្ធានកំប្លែងរបស់ "មេគ្រូនិងកូនគ្រូមួយក្រុម" ដែលច្រើនតែជា "វរជនពាលពុករលួយដល់ឆ្អឹង" ជាឈ្លើងចាស់ជញ្ជក់ឈាមគ្រូ សេសសល់អំពីរបបរាជនិយមសក្តិភូមិមុន ហើយដែលសព្វថ្ងៃកំពុងខំប្រឹងដើរតួជាតំណាងបុគ្គលិកសិក្សាខ្មែរយ៉ាងគឃ្លើនគ្មានខ្មាស់គ្មានអៀន ប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ទៅតាមធម្មជាតិដើមរបស់ខ្លួន ,

– ពុំព្រមប្រគល់គ្រឿងសម្ភារៈ ព្រមទាំងប្រាក់ប្រមាណប្រាំពីរលានរៀលដែលជាសម្បត្តិសមាគម ហើយដែលជាញើសជាឈាម របស់បុគ្គលិកសិក្សាភាគច្រើនដាច់ខាតដែលក្រខ្សត់រហេមរហាមនោះ ឱ្យទៅដល់ក្រុមគ្រូ ពុករលួយវង្វេងកំណើតនឹងពុលបុណ្យសក្តិទាំងនេះ យកទៅចាយវាយឡើយ,

– តំរូវឱ្យរដ្ឋាភិបាលដោះលែងជាបន្ទាន់ និងគ្មានលក្ខខណ្ឌ នូវតំណាងបុគ្គលិកសិក្សាខ្មែរ ២ រូប ដែលរដ្ឋាភិបាលបានចាប់ទៅឃុំឃាំង កាលពីថ្ងៃទី ២៥ - ៩ - ៧៤ ដោយអយុត្តិធម៌ ដោយរំលោភ ដូចដែលសេចក្តីថ្លែងការណ៍ចុះថ្ងៃ១២តុលា ១៩៧៤ នៃ " សមាគមខ្មែរដើម្បីការពារសិទ្ធិមនុស្ស " បាន

វែកញែកស្រាប់ ”

— បើចង់រំលាយសមាគមបុគ្គលិកសិក្សាខ្មែរខាំងពេក ទ្រាំពុំបាន ព្រោះសមាគមនេះពុំបានបំរើផលប្រយោជន៍ដ៏ខ្មៅងងឹតផ្ទាល់របស់ខ្លួន ដូចជាសមាគម “ខ្មែរកាត់ចិន” ឬ “ចិនសុទ្ធ” ៗទៃទៀតនោះ រដ្ឋាភិបាលត្រូវអនុញ្ញាតច្បាប់ជាពិសេសដើម្បីឱ្យសមាគមបុគ្គលិកសិក្សាខ្មែរ អាចបើកមហាសន្និបាតវិសាមញ្ញមួយ និងដើម្បីឱ្យសមាគមបុគ្គលិកសិក្សាខ្មែរអាចរំលាយខ្លួនឯងស្របទៅតាមប្រការទាំងឡាយ ដែលមានក្នុងលក្ខន្តិក·សមាគម ។ រួចសព្វគ្រប់ហើយ ចាំជិះសេះលែងដៃចុះ ព្រោះជាជោគជ័យមួយរយភាគរយហើយ ។

— រដ្ឋាភិបាលត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះមុខប្រវត្តិសាស្ត្រលើផលវិបាកទាំងឡាយដែលអាចនឹងកើតមានឡើងអំពីបញ្ហាថ្មីៗទៀតដែលរដ្ឋាភិបាលបានយកទៅចងបញ្ហាចាស់ៗ ដែលមានះមិនព្រមដោះស្រាយទៅតាមធម្មជាតិរបស់ខ្លួន ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ១៩៧៤

គណៈកម្មាធិការចំរុះតំណាងបុគ្គលិក
នៅមធ្យមសិក្សា និង បឋមសិក្សា
ក្រុងភ្នំពេញ និង ខេត្តខ្លះ

# ញត្តិរបស់បុគ្គលិកបឋមសិក្សា និង មធ្យមសិក្សា ខេត្តកណ្ដាល

– ដោយបានស្ដាប់ការផ្សាយរបស់វិទ្យុជាតិកាលពីថ្ងៃ ២៥ ខែកញ្ញា ឆ្នាំ ១៩៧៤ ស្ដីពីការរំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ដោយរដ្ឋាភិបាលបច្ចុប្បន្នរបស់លោក ឡុង បូរេត ។

– ដោយយល់ឃើញថា ការរំលាយសមាគមនេះបានប្រព្រឹត្តទៅ ផ្ទុយទាំងស្រុងទៅលើគោលការណ៍ប្រជាធិបតេយ្យ និង ជំរុញរបបគ្រប់គ្រងសព្វថ្ងៃទៅដល់ជំណាក់ការមួយគួរឲ្យព្រួយបារម្ភ ។

– ដោយយល់ឃើញថា រាល់សកម្មភាពរបស់គណៈកម្មធិការកណ្ដាលនៃសមាគម សុទ្ធតែស្របទាំងស្រុងនឹងឆន្ទៈរបស់បុគ្គលិកសិក្សា ព្រមទាំងប្រជាពលរដ្ឋខ្មែរទូទៅ ។

– ដោយយល់ឃើញថា ការដែលរដ្ឋាភិបាលបានចាត់ឲ្យអាជ្ញាធរទៅគាស់ទ្វារុសរើយកទ្រព្យសម្បត្តិរបស់សមាគម ចាប់ចងបុគ្គលិកសិក្សាពីររូបជាសមាជិកគណៈកម្មាធិការកណ្ដាលនៃសមាគមនេះ ជាសកម្មភាពមួយបង្ហាញឲ្យឃើញថា "រដ្ឋាភិបាលបច្ចុប្បន្នបានប្រព្រឹត្តផ្ទុយទាំងស្រុងនឹងឆន្ទៈរបស់បុគ្គលិកសិក្សា និងពលរដ្ឋទូទៅ" ។

ហេតុនេះយើងខ្ញុំជាបុគ្គលិកបឋមសិក្សានិងមធ្យមសិក្សាខេត្តកណ្ដាល

– *សូមគាំទ្រនិងទុកចិត្តទាំងស្រុង ទៅលើគណៈកម្មាធិការ-*

កណ្ដាល"ស.ប.ស.ខ" ដែលបានតែងតាំងឡើង ដោយមហា-សន្និបាតរបស់បុគ្គលិកសិក្សា ។

– សូមឱ្យគណៈកម្មការកណ្ដាល ស. ប. ស. ខ. នេះ បានបន្តសកម្មភាពរបស់ខ្លួនទៅទៀត ព្រោះមានតែគណៈកម្មាធិការកណ្ដាលនេះទេ ដែលមានសមត្ថភាពពេញលេញ មានចិត្តគំនិតស្មោះត្រង់ អាចការពារផលប្រយោជន៍របស់បុគ្គលិកសិក្សាបានពិតប្រាកដ ។

– សូមបដិសេធដាច់ខាតមិនទទួលស្គាល់ គណៈកម្មាធិការដែលលើកបន្តុបឡើងដោយរដ្ឋាភិបាលបច្ចុប្បន្ន ព្រោះថាអំពើនេះជាការឆក់ប្លន់យកសិទ្ធិរបស់បុគ្គលិកសិក្សា ។ ម្យ៉ាងទៀត "សមាសភាពនៃគណៈកម្មាធិការចាត់តាំងនេះ ពោរពេញទៅដោយជំពូកជនពុករលួយចាស់គំរិល ធ្លាប់កេងប្រវ័ញ្ច ផលប្រ-យោជន៍សមាគម ដែលបុគ្គលិកសិក្សាខ្មែរមិនទាន់ភ្លេចនៅឡើយ នូវអតីតកាលដ៏កខ្វក់របស់អស់លោកទាំងនោះ" ។

— សូមគណៈកម្មាធិការកណ្ដាល "ស.ប.ស.ខ." មេត្តាលើកឡើងនូវការតវ៉ាយ៉ាងម៉ឺងម៉ាត់ចំពោះរដ្ឋាភិបាល ដើម្បីឲ្យសមាគមបុគ្គលិកសិក្សាខ្មែរ "ស.ប.ស.ខ" មានសកម្មភាពឡើងវិញជាប្រក្រតី ។

ធ្វើនៅតាខ្មៅ ថ្ងៃទី១៤ តុលា ១៩៧៤

បុគ្គលិកបឋមសិក្សា និងមធ្យមសិក្សា

ខេត្តកណ្ដាល

# សេចក្ដីសំរេចចិត្តនៃបុគ្គលិកសិក្សា សាលាឃ្លាំងមឿង

បានឃើញសេចក្ដីសំរេចរបស់មហាសន្និបាតវិសាមញ្ញ សបស ៗ ចុះថ្ងៃទី ៥ មេសា ១៩៧៤ ដោយធ្វើការក្នុងមួយសប្ដាហ៍ ៣ ថ្ងៃ ។

បានឃើញសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ សបស ៗ ចុះថ្ងៃទី ២៣ កញ្ញា ១៩៦៤ ។

បានឃើញសេចក្ដីប្រកាសរបស់រដ្ឋាភិបាល ស្ដីពីការតំលើងថ្លៃប្រេងឥន្ធនៈ និង អង្ករ ពីថ្ងៃទី ១៥ កញ្ញា កន្លងទៅនេះ ។

បានឃើញស្ថិតិចំនួនសុំទិញអង្ករចុះ ៩០ ភាគរយ នៅគ្រប់គ្រឹះស្ថានសិក្សាក្នុងក្រុងភ្នំពេញមកពីខ្វះប្រាក់បង់ថ្លៃអង្ករ ។

បានឃើញសេចក្ដីសំរេចចិត្តរបស់គណៈកម្មាធិការនាយក នៃសមាគមខ្មែរការពារសិទ្ធិមនុស្សចុះថ្ងៃទី ១២ តុលា ១៩៥៥ ។

បានឃើញ និង ពិចារណាសព្វគ្រប់ថា " សព្វថ្ងៃនេះ ជីវភាពបុគ្គលិកសិក្សាគ្រប់រូបបានចុះដល់កំរិតអប្បបរិមា រស់ដើម្បីកំដរសង្គមខ្មែរដោយអយុត្តិធម៌ឥតន័យ " ។

ដើម្បីឲ្យធ្លើយនឹងប្រាក់បៀវត្សដែលរដ្ឋាភិបាលបច្ចុប្បន្នកំរិតឲ្យ ហើយនោះ យើងខ្ញុំជាបុគ្គលិកសិក្សា សាលាឃ្លាំងមឿង បានសំរេចចិត្តធ្វើការក្នុងមួយសប្ដាហ៍តែពីរ (២) ថ្ងៃគត់ ចាប់តាំងពីថ្ងៃជាឯកច្ឆន្ទថា

ទី ១ ខែវិច្ឆិកា ១៩៧៤ តទៅ ហើយនឹងបញ្ឈប់ការងារជាស្ថាពរទៀត បើលោកប្រធានាធិបតីមិនព្រមដោះស្រាយតាមញត្តិដែលបានជូនមក ។

ធ្វើនៅសាលាឃុំាំងមៀង ថ្ងៃទី ២១ តុលា ១៩៧៤

---

## ញត្តិនៃបុគ្គលិកនៅវិទ្យាល័យ ១៨ មីនា ១៩៧០

— ដោយយល់ឃើញថា តំលៃទំនិញនៅលើសាធារណរដ្ឋខ្មែរសព្វថ្ងៃ កាន់តែឡើងខ្ពស់ដាច់អំពីប្រាក់បៀវត្សរបស់បុគ្គលិកសិក្សា កាន់តែឆ្ងាយទៅៗ បណ្តាលឲ្យបុគ្គលិកសិក្សាអាចរស់មិនបានទាំងមួយអាទិត្យផង ដោយសារប្រាក់ខែបន្តិចបន្តួចរបស់ខ្លួន ។

— ដោយយល់ឃើញថា ការទាមទារ " សិទ្ធិរស់ " ជាហូរហែរបស់បុគ្គលិកសិក្សា ពុំគ្រាន់តែមិនបានទទួលការដោះស្រាយប៉ុណ្ណោះទេ គឺថែមទាំងបានទទួលការរករឿងព្យាបាទមួលបង្កាច់ ចាប់ដាក់គុក បាញ់សំលាប់យ៉ាងឃោរឃៅអំពីរដ្ឋាភិបាលនៃ " សាធារណរដ្ឋខ្មែរ " ដែលឡើងកាន់អំណាច តៗគ្នា ។

— ដោយយល់ឃើញថា សមាគមបុគ្គលិកសិក្សាខ្មែរជាពិសេសសេចក្តីថ្លែងការណ៍របស់សមាគមចុះថ្ងៃទី ២៣-០៩-៧៤ ដែលពុំយល់ស្របនឹងវិធានការតំលើងតំលៃទំនិញរបស់រដ្ឋាភិបាល និងដែលប្រកាស

ជកសេចក្ដីទុកចិត្តម្ដងទៀតអំពីរដ្ឋាភិបាល ឡុងណុល ឬរវេត ទី២ ពិតជាតំណាងឆន្ទៈរបស់បុគ្គលិកសិក្សាភាគច្រើនដាច់ខាត ។

— ដោយយល់ឃើញថា ការដែលអាជ្ញាធរនៃ "សាធារណរដ្ឋខ្មែរ" បានផ្ដើមវាយលុករំលាយសមាគមបុគ្គលិកសិក្សាខ្មែរ ដែលបានបំរើបុគ្គលិកសិក្សាខ្មែរជិត ៣០ ឆ្នាំមកហើយ ព្រមទាំងបានចាប់យកទៅឃុំឃាំងនូវសមាជិក ២ នាក់នៃគណៈកម្មាធិការកណ្ដាលសមាគមបុគ្គលិកសិក្សាខ្មែរកាលពីថ្ងៃទី ២៥-០៩-៧៤ នោះ ជាការរំលោភយ៉ាងឃោរឃៅទៅលើសិទ្ធិមនុស្ស ដូចដែលសេចក្ដីថ្លែងការណ៍របស់ "សមាគមខ្មែរដើម្បីការពារសិទ្ធិមនុស្ស" ចុះថ្ងៃទី ១២-១០-៧៤ បានលាតត្រដាងប្រាប់មតិមហាជនស្រាប់ ។

យើងទាំងអស់គ្នាជាបុគ្គលិកនៅវិទ្យាល័យ "១៨ មីនា ១៩៧០" សូមឲ្យសមាគមដ៏ចាស់ទុំរបស់បុគ្គលិកសិក្សានេះ កើតឡើងវិញ ដើម្បីបានការពារនិងបំរើផលប្រយោជន៍របស់បុគ្គលិកសិក្សាខ្មែរឡើងវិញ ហើយសូមប្រកាសជាឧឡារិកថា:

*— នៅតែទទួលស្គាល់ សមាគមបុគ្គលិកសិក្សាខ្មែរ "ស.ប.ស.ខ" ថាជាតំណាងឆន្ទៈ នៃបុគ្គលិកសិក្សាខ្មែរទាំងអស់,*

*— មិនទទួលស្គាល់ គ្រួរង្វេងកំណើតឈ្មក់បុណ្យសក្តិមុខក្រាស់គ្មានខ្មាសគ្មានអៀនមួយក្រុមតូចដែលកំពុងខំប្រឹងដើរ*

គួជាតំណាងបុគ្គលិកសិក្សាខ្មែរប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ,

– មិនព្រមប្រគល់សម្បត្តិទាំងអស់ ដែលជាកម្មសិទ្ធិនៃ .ស .ប .ស .ខ ឲ្យទៅក្រុម " តំណាងចាប់ផ្ដាក់ " ដែលច្រើនតែជាឈ្មើង ជាជនស្ដួយរលួយ សេសសល់អំពីសម័យសក្ដិភូមិរាជនិយមខាងលើនេះទេ ,

– ការរំលាយសមាគមនេះ ត្រូវធ្វើទៅតាមការបោះឆ្នោតនៃមហាសន្និបាតដែលស្របទៅតាមមាត្រា ដែលមានចែងនៅក្នុងលក្ខន្តិកៈនៃសមាគម,

– រដ្ឋាភិបាលត្រូវទទួលខុសត្រូវទាំងស្រុង លើផលវិបាកទាំងឡាយ ដែលអាចនឹងកើតមានឡើងអំពីល្បែងប្រឆាំងនឹងប្រជារាស្ត្រ ល្បែងផ្ដាច់ការផ្ដាប់ពណ៌របស់ខ្លួន ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ១៣ ខែ តុលា គ.ស.១៩៧៤

យើងខ្ញុំទាំងអស់គ្នាជាបុគ្គលិក

នៅវិទ្យាល័យ ១៨ មីនា ១៩៧០

តាំងពីបានផ្ញើបញ្ជីពីរសំណុំនោះមក គណៈកម្មាធិការកណ្ដាលពុំទាន់បានទទួលប្រតិកម្មអ្វីបន្តិចបន្តួចពីអង្គការជាន់ខ្ពស់នៅឡើយទេ ទោះបីក្នុងន័យណាដ៏ដោយ ៗ ផ្ទុយទៅវិញ គណៈកម្មាធិការកណ្ដាលនៅតែបានទទួលញត្តិប្រតិកម្មជាបន្តបន្ទាប់មកទៀត ដែលមានន័យស្រដៀងញត្តិមុនៗដែរ ។ នៅពេលដែលអាជ្ញាធរកំពូលពុំមានប្រតិកម្មនេះ បុគ្គលិកសិក្សានៃគ្រឹះស្ថានសិក្សាខ្លះបានអនុវត្តសេចក្ដីសំរេចចិត្តរបស់ខ្លួនរួចទៅហើយ គឺគេសំរេចធ្វើការតែ២ថ្ងៃក្នុងមួយសប្ដាហ៍នៅផ្នែកបឋមសិក្សា ៗ

ដំណាលគ្នានឹងពេលដែលបុគ្គលិកសិក្សា កំពុងតែគាំទ្រសមាគមបុគ្គលិកសិក្សានេះ ក្រុងមារក៏បង្កើតចលនាជំទាស់គ្រប់ទិសទីដែរ ។ នៅក្នុងមជ្ឈដ្ឋានបុគ្គលិកសិក្សា មានអ្នករត់ការដើរសូកនិងប៉ាវបាយយ៉ាងច្រេចច្រាច ដើម្បីគាំទ្រក្រុមអាចារ្យណុប ធុំ ប៉ុន្តែជោគជ័យមិនបានទទួលសមនឹងទឹកលុយដែលចាយសោះ ព្រោះការដែលគេធ្វើនោះដូចជាពុំប្រកបដោយសុទ្ធចិត្តឡើយគឺគ្រាន់តែជាសក្ខីភាពនៃទ្រឹស្ដីឡេមឡឹមប៉ុណ្ណោះឯង ៗ មតិមួយចំនួនយល់ឃើញថា ប្រសិនបើការនេះនៅតែប្រព្រឹត្តទៅដូច្នេះតែមួយឆ្នាំទៀត នោះថវិកាជាតិប្រហែលជាត្រូវហិនជាមិនខាន ៗ រីឯជោគជ័យឡាកនឹងត្រូវបានទៅឯថៅកែភោជនីយដ្ឋានឯណោះសោះ ៗ

កាលបើក្រុមឡេមឡឹមខ្មែរ-មនមុជរកជោគជ័យក្នុងចំណោមបុគ្គលិកសិក្សាមិនបានដូចបំណងដូច្នេះ គេក៏បើក Formation បែរក្បាលទៅខាងមេអ៊ីឡូត៍ - ចៅសង្កាត់ ៗល ៗ នានាម្ដងវិញ ក្រែងពួកអស់នោះមាន

នៅសល់ស្មៀតភ្ញៀខ្វះគ្រាន់នឹងប្រើ ។ មែន! យើងបានពត៌មានមកថា អភិបាលខណ្ឌទាំងអស់បានត្រូវគេញុំងស៊ុកត្រចៀក ឲ្យធ្វើញត្តិស្តីបន្ទោសសមាគមបុគ្គលិកសិក្សាខ្មែរ ហើយគាំទ្រក្រុមមេអាណានិគម ណុបធំ ។

យើងយល់ឃើញថា ប្រសិនបើអ្នកចុះហត្ថលេខា — ផ្តិតមេដៃគាំទ្រទាំងនោះដែលឋិតនៅក្រៅក្របខណ្ឌបុគ្គលិកសិក្សា បានយល់បញ្ហាបុគ្គលិកសិក្សាច្បាស់លាស់នោះជាការប្រសើរណាស់ ។ ប្រសិនបើគាំទ្រទាំងល្ងិតល្ងង់ឬចុះហត្ថលេខា — ផ្តិតមេដៃដោយគេបង្ខិតបង្ខំទេនោះ អំពើនេះគ្រាន់តែជាវិប្បដិសារីដ៏ក្តៅក្រហាយមួយទុកជាកេរ្តិ៍ឲ្យកូនចៅ និងសាច់សាលោហិតរបស់អស់លោក — អ្នកនាងតែប៉ុណ្ណោះឯង ។

ម៉្យាងទៀតប្រសិនបើអស់លោក-អ្នក-នាង ដែលមានចុះ ហត្ថលេខាក្តី ផ្តិតមេដៃក្តីដូចមានកស្តុងតាងជាគំរូខ្វះនៅលើទំព័របន្ទាប់ជាប់មកជាមួយនេះ មានវិចារណញ្ញាណឈ្វេងយល់ឃើញយ៉ាងជ្រាលជ្រៅ នូវតម្លៃនៃមូលនិធិសង្គមកិច្ច ដែលមានលោកអាចារ្យ ណុម ធំ ជាប្រធានចាប់ដាក់នោះ គប្បីអស់លោក អ្នក — នាងប្រញាប់ចូលជាសមាជិក ឲ្យសរាន់ទៅដើម្បីជួយក្រុមគាត់ផង ព្រោះក្រុមគាត់ចូលនិវត្តន៍ស្ទើរអស់ទៅហើយ ។

រឿងនេះ ( ការតម្រូវឲ្យគេចូលជាសមាជិកក្តី ការបង្ខិតបង្ខំគាត់លុយគេឬឲ្យគេធ្វើញត្តិគាំទ្រក្តី ) មនុស្សល្ងង់ណាក៏យល់ដែរថា វាជាល្បែងយកចង្អេរគ្របដំរីដេក ព្រោះថាសកម្មភាពបែបនេះគ្រាន់តែជាកស្តុតាងនៃគំនិតអាណានិគមខ្មែរ - មនពូនខ្លួនមួយបែប ក្នុងចំណោមទ្រឹស្តីប្រវញ្ចទាំងឡាយ

ដែលធ្លាប់តែមានជាហូរហែមកប៉ុណ្ណោះឯង ។ គេសង្ឃឹមថាបន្តិចទៀតនឹងមានញត្តិគាំទ្រផ្តិតមេដើងពីពួកក្នុង -មន- បាមខ្ញុំមកទៀតពុំខានឡើយ ។

សូមអ្នកអានទាំងឡាយពិនិត្យវាយតម្លៃញត្តិ - ហត្ថលេខា - ស្នាមផ្តិតមេដៃទាំងនេះតាមការគួរជងចុះ ។

---

# ញត្តិ

## នៃប្រជាពលរដ្ឋអ្នករដ្ឋការ ស៊ីវិល យោធា ខ័ណ្ឌដូនពេញ

សូមជំរាបមកលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ធម្មការ កំណែនទូទៅ សន្តិការកម្មនិងមហាសាមគ្គី ក្រុងភ្នំពេញ ។

តាមរយៈលោកឧបការីប្រធានាធិបតី នៃសាធារណរដ្ឋ ទទួលភារៈមើលការ ក្រុងភ្នំពេញ

ដោយយល់ឃើញថា សមាគមបុគ្គលិកសិក្សាខ្មែរ បានបង្កើតឲ្យមានការរំជើបរំជួលក្នុងផ្ទៃបុគ្គលិកសិក្សា និងប្រជាពលរដ្ឋ ដែលជាមាតាបិតានៃសិស្សជាច្រើនលើកច្រើនគ្រា ក្នុងរយៈពេលពីរឆ្នាំ ចុងក្រោយនេះ ។

- ដោយយល់ឃើញថា សមាគមបុគ្គលិកសិក្សាខ្មែរនេះ មិនបានបំរើផលប្រយោជន៍ពិតប្រាកដរបស់បុគ្គលិកសិក្សាភាគច្រើន ផ្ទុយទៅវិញជាឧបករណ៍របស់ជនមួយក្រុមតូចដែលជាភ្នាក់ងារបង្កប់ខ្លួនរបស់ខ្មាំង ។

— ដោយយល់ឃើញថា សមាគមបុគ្គលិកសិក្សាខ្មែរនេះក្លាយទៅជាអង្គការធ្វើនយោបាយបំរើផលប្រយោជន៍មនោគមវិជ្ជាខ្មាំង ជុយនឹងផលប្រយោជន៍នឹងឧត្តមគតិរបស់ប្រជាជាតិខ្មែរ នៃសាធារណរដ្ឋក្នុងកាលៈទេសៈក្នុងបច្ចុប្បន្ននេះ ?

— ដោយយល់ឃើញថា សមាគមបុគ្គលិកសិក្សាខ្មែរមិនគោរពនូវលក្ខន្តិកៈរបស់ខ្លួន ដែលចែងថាមិនត្រូវធ្វើនយោបាយ ហើយមិនគោរពច្បាប់រដ្ឋស្តីពីការរួមប្រជុំ ដែលប្រទេសជាតិស្ថិតនៅក្នុងភយន្តរាយ ។

— ដោយយល់ឃើញថា គណៈកម្មាធិការបណ្ដោះអាសន្ន គ្រប់គ្រងឥណទាន សង្គមកិច្ចបុគ្គលិកសិក្សាខ្មែរ ដែលមានលោកតា ណុប ធុំជាប្រធាន បានខិតខំធ្វើការទទួលតាំងពីពេលនោះមក ហើយបានទទួលលទ្ធ-ផលកាន់តែប្រសើរឡើងជាទីពេញចិត្តនៃបុគ្គលិកសិក្សាភាគច្រើនទូទៅ ។

— អាស្រ័យដោយហេតុដូចបានជំរាបខាងលើនេះហើយ យើងខ្ញុំជាប្រជាពលរដ្ឋ អ្នករដ្ឋការ ស៊ីវិល និងយោធា ខ័ណ្ឌដូនពេញទាំងមូលសុំរេចចិត្តដូចតទៅ ៗ

១- សូមគាំទ្រវិធានការរដ្ឋាភិបាល ដែលរំលាយសមាគមបុគ្គលិកសិក្សាខ្មែរចោល ។

២- សូមគាំទ្រវិធានការរដ្ឋាភិបាល ដែលបានបង្កើតគណៈកម្មាធិការបណ្ដោះអាសន្នគ្រប់គ្រងឥណទានសង្គមកិច្ចនៃបុគ្គលិកសិក្សាខ្មែរ ហើយ

សូមរដ្ឋាភិបាលទុកអង្គការនេះ ឲ្យបំពេញបេសកកម្មបុគ្គលិកសិក្សាខ្មែរតទៅទៀត ។

៣- សូមអំពាវនាវឲ្យរដ្ឋាភិបាលចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីកុំឲ្យអតីតៈសមាគមបុគ្គលិកសិក្សាខ្មែរមានរូបរាងឡើងវិញ ដែលជាហេតុនាំឲ្យភ្នាក់ងារខ្មាំងយកអង្គការនេះ ធ្វើជាឧបករណ៍សំរាប់បង្កបង្កើតការរំជើបរំជួលជ្រួលច្របល់ដូចពេលមុនៗតទៅទៀត ។

ភ្នំពេញ, ថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ១៩៧៤

ប្រជាពលរដ្ឋ អ្នករដ្ឋការ ស៊ីវិល និង យោធា ខ័ណ្ឌដូនពេញ

[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]

[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]

យើងរៀបចំចងក្រងសៀវភៅនេះទុកជានិមិត្តរូបនៃការសូត្រមន្តរំដោះគ្រោះដល់សមាគមបុគ្គលិកសិក្សាខ្មែរ ដែលបានត្រូវអាជ្ញាធរលបវាយពីខាងក្រោយខ្នងយ៉ាងកំសាក ។

សមាគមនេះទោះបីស្លាប់ក្តី រស់ឡើងវិញក្តី អាស្រ័យលើគំនិតគស្ហំនៃសមាជិកគ្រប់រូប ដែលយល់យ៉ាងច្បាស់ នូវមូលហេតុដ៏ត្រឹមត្រូវរបស់ខ្លួនដែលសមាគមបានបំរើជារៀងរាបដរាបមក ជាពិសេសក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយនេះ ដែលសមាគមបានពាំងឧបសគ្គសព្វយ៉ាងក្នុងការតស៊ូដើម្បីជួយសម្រួលជីវភាពទាំងអស់គ្នា ជាពិសេសជីវភាពគ្រូបង្រៀនបឋមសិក្សា ដែលសព្វថ្ងៃមិនទាន់ទាំងបានរលាស់កចេញផុតពីនឹមដែកនៃអធិការបឋមសិក្សាអាណានិគមមួយចំនួននៅឡើយផងនោះ ។

គណៈកម្មាធិការកណ្តាលបច្ចុប្បន្ន ពុំដែលគិតហើយថែមទាំងពុំដែលបានគិតថាមានចិត្តក្បត់នឹងមូលហេតុដ៏ត្រឹមត្រូវ ឬប្រវញ្ចសមាជិកណាមួយសោះឡើយ ។ សេចក្តីសំរេចទាំងឡាយរបស់មហាសន្និបាតតែងតែបានត្រូវគណៈកម្មាធិការកណ្តាលអនុវត្តយ៉ាងរហ័ស និងជិតដល់ជានិច្ច ។ សេចក្តីថ្លែងការណ៍ទាំងឡាយណា ដែលបានធ្វើរួចទៅហើយនោះ សេចក្តីថ្លែងការណ៍ទាំងឡាយនោះសុទ្ធតែបិតនៅក្នុងក្របខណ្ឌបំរើបុគ្គលិកសិក្សាជាពិសេស និងបំភ្លឺអ្នកកាន់កាប់អំណាច ព្រមទាំងជួយសាធារណជនជាទូទៅ។ប្រសិនបើមានសមាជិកណាមួយយល់ផ្ទុយទៅវិញ

យើងសមាជិកនៃគណៈកម្មាធិការកណ្តាល (លើកលែងតែសមាជិកខ្លះដែលបានលក់ខ្លួនទៅហើយ និងលួចលួយជាមួយគេ ២ ៣) មិនដែលញាក់នឹងប្រគល់ខ្លួនឲ្យមហាសន្និបាតសាមញ្ញឬវិសាមញ្ញកាត់ទោសឡើយ ព្រោះថា យើងដែលជាក្រុមទទួលខុសត្រូវខាងគណៈកម្មាធិការកណ្តាលនេះ រមែងស្អប់ខ្ពើមជានិច្ចនូវអ្វីដែលជាអប្រជាធិបតេយ្យ និងអ្វីដែលគេហៅថា "មិនស្របច្បាប់នោះ" ។

## នៅទីបំផុត យុត្តិធម៌ត្រូវតែឈ្នះអយុត្តិធម៌

តម្កល់ទុកតាមច្បាប់លេខ ៦៨៧ ចុះថ្ងៃទី ១៣ - ១២ - ៧៤
បោះពុម្ពលើកទី ១ ចំនួន ៣.០០០ ក្បាល

រោងពុម្ព មហាលាភ លេខ ២៨២
ផ្លូវជ្រុងមហាវិថី ប្រជាធិបតេយ្យ - ខណ្ឌ៧មករា ភ្នំពេញ

# គំនុចណ្ណះ

១- យប់យន់ងងឹតចិត្តឈឺចាប់ ជន្ទពាលអាងច្បាប់ចាប់ចោទមូល
អំណាចគ្រប់គ្រាន់ផាន់ផ្តាច់ផ្តួល ផាតិយ៉ាប់ថាស្រួលស្រុកសប្បាយ។

២- គំនិតកំហូចពួជជិះជាន់ បំភ័យបំភាន់ជនគ្រប់កាយ
គ្រួសារក្រីក្រក្តៅក្រហាយ មូលធនរៀងអាយសប្បាយរស់ ។

៣- អាងឃ្នាងអាងខ្មោះគុកច្រវាក់ ជិះជាន់តាមថ្នាក់ប្រាក់-សក្តិ-យស
សំលេងពលរដ្ឋស្រែកសុំរស់ ជនចោរទុយ៉ិសវាយបង្ក្រាប ។

៤- វណ្ណៈមូលធនជនហុតឈាម កំហែងគំរាមតាមផ្លូវបាប
រាស្ត្រណាហ៊ានក្រោកកិនពង្រាប កាច់មូលចងតាបបាញ់ប្រហារ ។

៥- អំណាចរដ្ឋមួយស្ទួយមូលធន សំលុតមហាជនជាសាធារណ៍
ប្រើ «ច្បាប់ផ្តាច់ការ» រឹបជាន់គ្នា បំពានបំពារសិទ្ធិជាតិ ។

៦- រស់ជាប់អំណាចកាចឃោរឃៅ តូចធំ ស ខ្មៅ ប្រឹងខ្នីឃ្នាត
អាងបុណ្យប្រឹងបូមបឺតឈាមជាតិ គំនិតមារយាទធាតុវាក្សត់ ។

៧- ឆក់ប្លន់អំណាចប្រជាជន បំបិនមូលធនជាន់សង្កត់
មហាជនថាឈឺវាឲ្យអត់ ហ៊ានរើចោទក្បត់ចាប់ញាត់គុក ។

៨- សំលេងឈឺចាប់នៃមហាជន រស់រងទុក្ខធ្ងន់ពុនមហាទុក្ខ
នៅក្នុងសង្គមរលួយពុក អ្នកធំស្រណុកទុក្ខអ្នកក្រ ។

៩- សំលេងទាមទាររកក្តីសុខ រំដោះទោសទុក្ខចេញពីក
អំណាចចក្រពត្តិភ័យវឹកវរ មហាជនក្រោកឈរវាយបំបាក់ ។

១០- អំណាចជិះជាន់ភាន់ភ័យភិត ចោរឈ្មួញទុច្ចរិតពិតអស់លក្ខណ៍
ស្ងួនស្ងោស្ងីតស្ងៃងភ័យសស្លាក់ អាងចាក់អាងធាក់លែងយល់អ្វី ។

១១- ហាមាត់បើកភ្នែកស្រែកទាមទារ ដោះទុក្ខវេទនាជនប្រុសស្រី
ហ៊ានប្តូរជីវិតចិត្តភក្តី ស្នួយជាតិទឹកដីដែនកម្ពុជា ។

១២- ទោះទោសឧក្រិដ្ឋ ចិត្តមិនខ្លាច ប្រឆាំងអំណាចកាចឫស្យា
លត់ដំស្មារតីឲ្យភ្លៀវក្លា ប្តូរផ្ទជីវាដោយរីករាយ ។

អ៊ុត - ធន

ស្រង់ចេញពីទស្សនាវដ្តីមហាវិទ្យាល័យ អក្សរសាស្ត្រ មនុស្សសាស្ត្រ លេខ ១៩

តម្លៃ